| អ្នកត្រូវការ**ឧបត្ថម្ភការបំប៉នចំណីដោយប្រើ IV ឬបំពង់បញ្ចូលអាហារ;** <u>និង</u><br><br>កាឡូរីសរុបរបស់អ្នកដែលបានទទួលដោយ IV ឬបំពង់បញ្ចូលគឺយ៉ាងតិចណាស់ 25%; <u>និង</u><br><br>លោហធាតុរបស់អ្នកដែលទទួលយកតាមរយៈ IV ឬបំពង់គឺមានចំនួនច្រើនជាង 2 ពែងក្នុងមួយថ្ងៃ។ | 2 ដងឬច្រើនជាង |
| **អុកស៊ីហ្សែនតាមការពាក់ម៉ាស់ឬបំពង់សុស** | 11 ដងឬច្រើនជាង |
| **ការមើលថែរបួសការវះកាត់** | 2 ដងឬច្រើនជាង |
| **ឈឺចាប់រាល់ថ្ងៃ**មានន័យថា អ្នកមានបទពិសោធន៍ចំនួនខ្លះនៃការឈឺចាប់រៀងរាល់ថ្ងៃ។. | 15 ដងឬច្រើនជាង |
| **ជម្ងឺប៉ាគិនសុនឬជម្ងឺសរសៃប្រសាទ** | 15 ដងឬច្រើនជាង |
| **កម្មវិធីទំហំរង្វង់ចលនាដែលសន្លាក់អាចធ្វើបាន** គឺបង្កើតឡើងដោយអ្នកមានវិជ្ជាជីវៈ (គិលានុបដ្ឋាកឬអ្នកព្យាបាលរោគ)។ កម្មវិធីរក្សាភាពបត់បែននិងចលនាដែលមានប្រយោជន៍ក្នុងសន្លាក់នៃរាងកាយ។ | 11 ដងឬច្រើនជាង |
| **ចលនាដំណើរនៃឆ្អឹងបាក់** | 15 ដងឬច្រើនជាង |
| **រោគខ្វិន** (ពិការគ្រប់ទាំងជើងនិងដៃ) | 15 ដងឬច្រើនជាង |
| **ការព្យាបាលតាមវិទ្យុសកម្ម ឬការផ្សាំសរីរាង្គដោយប្រើវិទ្យុសកម្ម** | 11 ដងឬច្រើនជាង |
| **ជំងឺហើមសន្លាក់ឆ្អឹង** | 15 ដងឬច្រើនជាង |

| | |
|---|---|
| អ្នកមាន**បញ្ហាហើមពេលបច្ចុប្បន្ន** <u>និង</u>អ្នកត្រូវការជំនួយក្នុងការបរិភោគ។ | 11 ដងឬច្រើនជាង |
| **ដំបៅរលាក** (ពងស្បែកពីគេងយូរ) ជាមួយ:<br><br>**កន្លែងមួយ ឬកន្លែងជាច្រើននៃស្បែកពណ៌ក្រហមមិនងាយសះស្បើយ** (ដោយគ្មានការរលាត់ស្បែក) ដែលមិនបាត់ទៅណា នៅពេលសម្ពាធធូរស្បើយនៅត្រង់ចំណុចសម្ពាធ;<br><br>**ចំណែកការរលាត់ស្បែកបាត់** មួយកន្លែងឬច្រើនកន្លែង នៅលើខ្លួនដែលហាក់ដូចជារលាត់, ពងសើស្បែក, ឬដំបៅស្បែកបើកមុខនៅត្រង់ចំណុចសម្ពាធ; ឬ។<br><br>**កម្រាសទាំងស្រុងនៃការបាត់បង់ស្បែក** ត្រង់កន្លែងចំណុចសង្កត់ខ្លាំង ដែលឃើញហាក់ដូចជាបើកមុខកហូងជ្រៅ។  អ្នកអាចមើលឃើញសាច់ដុំឬស្បែក។<br><br><u>ឬ</u><br><br>**ស្បែកលែងដឹងការឈឺចាប់និង/ឬសម្ពាធ:**  អ្នកមិនអាចមានអារម្មណ៍ឈឺឬមានសម្ពាធក្នុងមួយកន្លែងឬច្រើនកន្លែងនៅ លើខ្លួនរបស់អ្នក។.<br><br><u>ឬ</u><br><br>**ដំបៅបើកមុខ(ទាំងឡាយ):**  ដំបៅបើកមុខគឺជាបូសឬដំបៅស្បែកផ្សេងៗឯទៀត។  ដោយមិនរួមបញ្ចូលការរលាត់, កន្ទួលរមាស់, ឬដាច់របួសទេ។<br><br><u>ឬ</u><br><br>**ដំបៅឈាមកក (ដាច់សរសៃឈាម) លើសើស្បែក:**  ដំបៅកកឈាម ឬដាច់សរសៃឈាមលើសើស្បែកគឺជាដំបៅ លើផ្នែករាងកាយដែលមានការរាំងស្ទះចលនាឈាម។  ដំបៅអាចចំហឬបិទ។  ជាទូទៅគេឃើញមានកើតនៅលើ ជើងផ្នែកខាងក្រោម ឬកែងជើង។.<br><br><u>និង</u><br><br>ការមើលថែដំបៅ ដែលមានរួមទាំងអន្តរាគមន៍ណាមួយសំរាប់ការព្យាបាលដំបៅតាមកំរិតដំបៅណាមួយ; ឬ<br><br>**របស់ប្រើមានបាញ់ខ្យល់ចេញ** ដែលមានរួមទាំងក្រម្ទូនទន់, ខ្យល់, ឬទ្រនាប់ដទៃទៀតសំរាប់កៅអី និងខ្យល់បញ្ចូទឹក ក្នុងពូក, | 2 ដងឬច្រើនជាង |

| | |
|---|---|
| គ្រែម៉ាស៊ីនប្រើខ្យល់ឲ្យទាប, ពូកបន្ថែតនិងទឹកឬពូកពពុះសាប៊ូ; ឬ<br><br>**កម្មវិធីការប្រែត្រឡប់ខ្លួន/ការប្រែកន្លែង:** កម្មវិធីបន្តជានិច្ចនិងស្ថិតស្ថេរសំរាប់ការផ្លាស់ប្តូរប្រែខ្លួនដើម្បីការពារ ស្បែកកុំឲ្យបែកស្រកា; ឬ<br><br>**ការអនុវត្តន៍នៃការរុំដំបៅ; ឬ**<br><br>**របួស/ ការមើលថៃស្បែក:** ទាំងនេះគឺជាការប៉ាន់ប្រមាណដើម្បីព្យាបាលកន្លែងស្បែកដាច់, ដំបៅ, ឬការដាច់នៅក្រោយពេលវះកាត់ដើម្បីធ្វើឲ្យជា។ | |
| **ការផុបខ្យល់** | 2 ដងឬច្រើនជាង |
| **ការមើលថៃកន្លែងវះដាក់បំពង់** | 11 ដងឬច្រើនជាង |
| **ម៉ាស៊ីនខ្យល់ដកដង្ហើមឬម៉ាស៊ីនអុកស៊ីហ្សែន** | 11 ដងឬច្រើនជាង |
| **ការហាត់ដើរ:** ការហាត់នេះគឺបានបង្កើត និងត្រួតត្រាឡើងដោយអ្នកមានវិជ្ជាជីវ: ((គិលានុបដ្ឋាក ឬអ្នកព្យាបាលរោគ) សំរាប់ការធ្វើសម្បទារឬក្នុងគោលបំណងឲ្យត្រឡប់ជាដូចដើម។ អ្នកផ្តល់ការមើលថៃធ្វើការបង្ហាត់យ៉ាងតិច 15 នាទីរៀងរាល់ថ្ងៃ។ | 11 ដងឬច្រើនជាង |

## ការមើលថៃដោយលើកលែង:

ការមើលថៃដោយលើកលែងគឺជាប្រភេទនៃការមើលថៃដែលតំរូវការប្រមូលផ្តុំនៃសេចក្តីមើលថៃជាក់ច្បាស់។ គឺមានមធ្យោបាយពីរយ៉ាងដើម្បីសិទ្ធិសំរាប់ការមើលថៃដោយលើកលែង។

## សិទ្ធិទទួលនៅក្រោមវិធីសាស្រ្ត #1:

អ្នកត្រូវតែជួបតាមគ្រប់លក្ខណៈវិនិច្ឆ័យទាំងបួនដែលមានរាយនៅខាងក្រោមដើម្បីមានគុណសម្បត្តិ។.

1. ADL ដែលមានពិន្ទុ 22 ឬច្រើនជាង; និង

2. សេចក្តីត្រូវការសំរាប់កម្មវិធីការប្រែខ្លួន/ការប្តូរកន្លែង; និង

3. ការព្យាបាលដែលមានសិទ្ធិទទួល, របស់របរប្រើប្រាស់ក្នុងផ្ទះ, និងជំនួយជាក់ច្បាស់ដែលអ្នកត្រូវការ ដែលទាក់ទងនឹងការទោបង្គន់; និង

4. សេចក្តីត្រូវការសំរាប់កម្មវិធីទំហំរង្វង់ចលនាដែលបានផ្តល់ឲ្យដោយអ្នកមើលថែមានគុណសម្បត្តិដែលបានបង់ឈ្នួល ឲ្យដោយក្រសួង DSHS

តារាងនៅខាងក្រោមរាយអំពីការតំរូវ 2-4 នៅក្នុងភាពដ៏លំអិត។

**2. កម្មវិធីការត្រឡប់ខ្លួន/ការប្រែកន្លែង:** កម្មវិធីនៅតែបន្តនិងរក្សាភាពទឹងទរសំរាប់ ការផ្លាស់ប្តូរកន្លែងដល់រាងកាយអ្នក ដើម្បីការពារការរលាកស្បែកអ្នក (ពងស្បែកពីគេងយូរ)។

**3. ការព្យាបាល, ប្រដាប់ប្រើប្រាស់ក្នុងផ្ទះ, ឬជំនួយដាក់ច្បាស់ដែលអ្នកត្រូវការ ដែលទាក់ទងនឹងការទៅបង្គន់ ដែលត្រូវសំរេចឲ្យមុនគេ។**

**ត្រូវតែរួមបញ្ចូលមួយពាក្យឬច្រើនដូចតទៅនេះ:**

- បំពង់បង្ហូរសំណល់មកខាងក្រៅ
- បំពង់បង្ហូរអចិន្ត្រៃយ៍ចេញពីខ្លួន
- បំពង់បង្ហូរខាងក្នុង
- កម្មវិធីបន្ទោរបង់លាមក : កម្មវិធីធម្មតាឬបន្តជានិច្ច ដែលអាចមានអន្តរាគមន៍នានា ជាជាងការប្រើថ្នាំលេប តាមមាត់ ដូចជាថ្នាំជួយឲ្យជំរុញ, ថ្នាំសុលនៅតាមហាងឬការបូមទឹកលាងពោះវៀន។
- ការមើលថែរបួសការវះកាត់
- ការពឹងពាក់ទាំងស្រុងមានន័ថា អ្នកមិនអាចធ្វើអ្វីដែលទាក់ទងនឹងការទៅបង្គន់បាន។ អ្នកមិនអាចឡើងចុះពីបង្គន់បាន, ពីកៅអីកន្ទោរនៅក្បែរគ្រែឬកន្ទោរបាន។ អ្នកមិនអាចជូតឬសំអាតខ្លួនឯង, ការប្តូរសំឡីអនាម័យឬខោទ្រនាប់, និងតំរង់សំលៀកបំពាក់បាន។ បើអ្នកមិនប្រើប្រាស់បង្គន់ អ្នកត្រូវពឹងពាក់ទាំងស្រុងទៅលើជនណាម្នាក់សំរាប់ជំនួយ ក្នុងការប្រើបំពង់បង្ហូរ, ចង់ផ្តកលាមកនៅខាងក្រៅខ្លួន, កៅអីកន្ទោរ, ឬបំពង់បង្ហូរទឹកនោម។

**4. កម្មវិធីទំហំរង្វង់ការធ្វើចលនា:** កម្មវិធីទំហំរង្វង់ការធ្វើចលនាគឺបង្កើតឡើងដោយអ្នកមានវិជ្ជាជីវៈ (គិលានុបដ្ឋាក ឬអ្នកព្យាបាលរោគ)។ កម្មវិធីរក្សាភាពស្ទុកស្ទាញ និងចលនាដែលមានប្រយោជន៍នៅត្រង់សន្លាក់នៃរាងកាយ។ គឺមាន ពីរប្រភេទនៃកម្មវិធីទំហំរង្វង់ចលនា។

**កម្មវិធីនៃវង្វង់ធ្វើចលនារបស់សន្លាក់:** ទាំងនេះគឺការហាត់ប្រាណដែលអ្នកធ្វើដើម្បីរក្សាចលនាសន្លាក់របស់អ្នក។ អ្នកប្រហែលត្រូវការជំនួយជាមួយនឹងការឲ្យសញ្ញាឬការរំលឹកពីអ្នកផ្តល់ការមើលថែ។.

ឬ

**កម្មវិធីទំហំវង្វង់ចលនាដែលសន្លាក់អាចធ្វើចលនាបាន (អ្នកត្រូវតែមានអាយុលើសពី 3 ឆ្នាំ):** អ្នកមិនអាចធ្វើចលនា សន្លាក់បាន ហើយអ្នកត្រូវការអ្នកមើលថែ ជួយធ្វើចលនាសំរាប់សន្លាក់និមួយៗ។

បើអ្នករស់នៅតាមផ្ទះ, កម្មវិធីទំហំវង្វង់ចលនាត្រូវតែផ្តល់ឲ្យដោយ: អ្នកផ្តល់ការមើលថែឯកត្តជន (IP), ទីភ្នាក់ងារអ្នកផ្តល់ការមើលថែ, ការថែរក្សាភារៈកិច្ចឯកជន, ឬការមើលថែតាមការណែនាំខ្លួនឯង (IP ប៉ុណ្ណោះ)។ បើអ្នករស់នៅតាមការរៀបចំនៃមន្ទីរមើលថែ គឺត្រូវតែផ្តល់ដោយ: មន្ទីរមើលថែមនុស្សធំ/មន្ទីរបុគ្គលិកមានផ្តល់អាហារ, មន្ទីរគ្រូពេទ្យ RN/LPN , មន្ទីរបុគ្គលិកមើលថែ, ឬមន្ទីរថែរក្សាកិច្ចការឯកជន, ឬអ្នកតំណាងគិលានុបដ្ឋាយិកា។.

## សិទ្ធិទទួលនៅក្រោមវិធីសាស្រ្ត #2:

អ្នកត្រូវតែជួបតាមគ្រប់លក្ខណៈវិនិច្ឆ័យទាំងប្រាំដែលមានរាយនៅខាងក្រោមដើម្បីមានគុណសម្បត្តិ។.

1. ADL ដែលមានពិន្ទុ 22 ឬច្រើនជាង; និង

2. សេចក្តីត្រូវការសំរាប់កម្មវិធីការប្រែខ្លួន/ការប្តូរកន្លែង; និង

3. សេចក្តីត្រូវការសំរាប់កម្មវិធីទំហំវង្វង់ចលនាដែលបានផ្តល់ឲ្យដោយអ្នកមើលថែមានគុណសម្បត្តិដែលបានបង់ប្រាក់ ឲ្យដោយក្រសួង DSHS; និង

4. ការឧបត្ថម្ភការបំប៉នអាហារតាម IV ឬបញ្ចុកតាមបំពង់ ដែលចំនួនកាឡូរីទាំងអស់ដែលបានទទួលក្នុងការដាក់ IV ម្តងឬតាមបំពង់ម្តង មានចំនួនច្រើនជាង 50% និងបញ្ចូលលោហធាតុតាម IV ឬបំពង់គឺច្រើនជាង 2 ពែង; និង

5. សេចក្តីត្រូវការសំរាប់ការលាងសំអាតឈាមដោយប្រើម៉ាស៊ីន ឬម៉ាស៊ីនខ្យល់ដកដង្ហើម/ម៉ាស៊ីនអុកស៊ីហ្សែន ដែលជួយផ្តល់ឲ្យដោយអ្នកមើលថែមានគុណសម្បត្តិដែលបានបង់ឈ្នួលឲ្យដោយក្រសួង DSHS

តារាងនៅខាងក្រោមរាយអំពីការគាំទ្រ 2-5 នៅក្នុងភាពដ៏លំអិត។

2. **កម្មវិធីការគ្រឡប់ខ្លួន/ការប្រែកន្លែង:** កម្មវិធីនៅតែបន្តនិងរក្សាភាពទឹងទរសំរាប់ ការផ្លាស់ប្តូរកន្លែងដល់រាងកាយអ្នក ដើម្បីការពារការរលាកស្បែកអ្នក (ពងស្បែកពីគេងយូរ)។.

3. **កម្មវិធីទំហំរង្វង់ការធ្វើចលនា:** កម្មវិធីទំហំរង្វង់ការធ្វើចលនាគឺបង្កើតឡើងដោយអ្នកមានវិជ្ជាជីវៈ (គិលានុបដ្ឋាក ឬអ្នកព្យាបាលរោគ)។ កម្មវិធីរក្សាភាពស្មុកស្មាញ និងចលនាដែលមានប្រយោជន៍នៅត្រង់សន្លាក់នៃរាងកាយ។ គឺមាន ពីរប្រភេទនៃកម្មវិធីទំហំរង្វង់ចលនា។

**កម្មវិធីទំហំរង្វង់ចលនាដែលសន្លាក់អាចធ្វើចលនាបាន:** ទាំងនេះគឺជាការហាត់ប្រាណដើម្បីរក្សាទម្ងើនៃសន្លាក់របស់ អ្នក។ អ្នកប្រហែលត្រូវការជំនួយជាមួយការផ្តល់សញ្ញា ឬការរំលឹកដោយអ្នកផ្តល់ការមើលថែ។

ឬ

**កម្មវិធីទំហំរង្វង់ចលនាដែលសន្លាក់អាចធ្វើចលនាបាន (អ្នកត្រូវតែមានអាយុលើសពី 3 ឆ្នាំ):** អ្នកមិនអាចធ្វើចលនា សន្លាក់បាន ហើយអ្នកត្រូវការអ្នកមើលថែ ជួយធ្វើចលនាសំរាប់សន្លាក់និមួយៗ។

បើអ្នករស់នៅតាមផ្ទះ, កម្មវិធីទំហំរង្វង់ចលនាត្រូវតែផ្តល់ឲ្យដោយ: អ្នកផ្តល់ការមើលថែឯកត្តជន (IP), ទីភ្នាក់ងារអ្នកផ្តល់ការមើលថែ, ការថែរក្សាភារៈកិច្ចឯកជន, ឬការមើលថែតាមការណែនាំខ្លួនឯង (IP ប៉ុណ្ណោះ)។ បើអ្នករស់នៅតាមការរៀបចំនៃមន្ទីរមើលថែ គឺត្រូវតែផ្តល់ដោយ: មន្ទីរមើលថែមនុស្សធំ/មន្ទីរបុគ្គលិកមានផ្តល់អាហារ, មន្ទីរគ្រូពេទ្យ RN/LPN , មន្ទីរបុគ្គលិកមើលថែ, ឬមន្ទីរថែរក្សាកិច្ចការឯកជន, ឬអ្នកតំណាងគិលានុបដ្ឋាយិកា។

4. **ការឧបត្ថម្ភការបំប៉នអាហារ/ភេសជ្ជ: ខាងក្រោមទាំងបីនេះគឺត្រូវគាំទ្រ។.**

- អ្នកត្រូវការឧបត្ថម្ភការបំប៉នចំណីដោយប្រើ IV ឬបំពង់បញ្ចូលអាហារ;
- កាឡូរីសរុបរបស់អ្នកដែលបានទទួលដោយ IV ឬបំពង់បញ្ចូលគឺយ៉ាងតិចណាស់ 50%;
- លោហធាតុរបស់អ្នកដែលទទួលយកតាមរយៈ IV ឬបំពង់គឺមានចំនួនច្រើនជាង 2 ពែងក្នុងមួយថ្ងៃ។.

5. **ការលាងសំអាតឈាមដោយប្រើម៉ាស៊ីន ឬការឧបត្ថម្ភម៉ាស៊ីនខ្យល់ដកដង្ហើម/ម៉ាស៊ីនអុកស៊ីហ្សែន:** អ្នកត្រូវការ ជំនួយដោយប្រើម៉ាស៊ីនខ្យល់ដកដង្ហើមឬម៉ាស៊ីនអុកស៊ីហ្សែន ឬជាមួយនឹងការយកជាតិពុលចេញពីឈាម មកពីអ្នក

ផ្តល់ការមើលថែដែលមានគុណសម្បត្តិបង់ប្រាក់ដោយក្រសួង DSHS: អ្នកផ្តល់ការមើលថែឯកត្តជន (IP), ទីភ្នាក់ងារអ្នកផ្តល់ការមើលថែ, ការថែរក្សាមានកាតព្វកិច្ចឯកជន, ឬការមើលថែតាមការណែនាំខ្លួនឯង (IP ប៉ុណ្ណោះ)

**ការលាងសំអាតឈាមដោយប្រើម៉ាស៊ីន ឬការគាំទ្ររបស់ម៉ាស៊ីនខ្យល់ដកដង្ហើម/ម៉ាស៊ីនអុកស៊ីហ្សែន:** អ្នកត្រូវការជំនួយដោយប្រើម៉ាស៊ីនខ្យល់ដកដង្ហើមឬម៉ាស៊ីនអុកស៊ីហ្សែន ឬជាមួយនឹងការលាងសំអាតឈាមដោយប្រើម៉ាស៊ីនមកពីអ្នផ្តល់ការមើលថែដែលមានគុណសម្បត្តិបង់ប្រាក់ដោយក្រសួង DSHS។ បើអ្នករស់នៅតាមផ្ទះ ជំនួយត្រូវតែ ផ្តល់ដោយ: អ្នកផ្តល់ការមើលថែឯកត្តជន (IP), ទីភ្នាក់ងារអ្នកផ្តល់ការបំរើ, ការថែរក្សាភារៈកិច្ចឯកជន, ឬការមើលថែតាមការណែនាំខ្លួនឯង (IP ប៉ុណ្ណោះ)។ បើអ្នករស់នៅតាមការរៀបចំនៃមន្ទីរមើលថែ គឺត្រូវតែផ្តល់ ដោយ: មន្ទីរមើលថែមនុស្សធំ/មន្ទីរបុគ្គលិកមានផ្តល់អាហារ, មន្ទីរគ្រូពេទ្យ RN/LPN , មន្ទីរបុគ្គលិកមើលថែ, ឬមន្ទីរថែរក្សាកិច្ចការឯកជន, ឬអ្នកតំណាងគិលានុបដ្ឋាយិកា។

## ការឧបត្ថម្ភក្រៅផ្លូវការ:

ការឧបត្ថម្ភក្រៅផ្លូវការគឺជួយអ្នកឲ្យទទួលអ្វីៗពីមិត្តសំឡាញ់, អ្នកជិតខាង, ឬសមាជិកគ្រួសារ។ ការឧបត្ថម្ភក្រៅផ្លូវការ ក៏មានរួមទាំងកម្មវិធីនានា ដូចជាថ្ងៃសុខភាពមនុស្សធំ ឬធនធានសហគមន៍ ដូចជាក្រុមវិហារកាតូលិកជាដើម។ លើកលែងតែកម្មវិធីខ្លះដូចជាថ្ងៃសុខភាពមនុស្សធំ, យើងមិនបង់ឈ្នួលឲ្យសំរាប់ការឧបត្ថម្ភក្រៅផ្លូវការទេ។ បើអ្នកមាន ការឧបត្ថម្ភក្រៅផ្លូវការ អ្នកនឹងបានទទួលម៉ោងសេវាដែលមានបង់ប្រាក់តិចជាងពីរឬបីម៉ោង នៅពេលអ្នកទទួលសេវា មើលថែផ្ទាល់ខ្លួននៅផ្ទះរបស់អ្នក។ (យើងមិនមើលពីការឧបត្ថម្ភក្រៅផ្លូវការទេ បើអ្នកនៅក្នុងមន្ទីររៀបចំពលរដ្ឋ ដូចជាមន្ទីរមើលថែមនុស្សធំ ឬមន្ទីរមើលថែដែលមានផ្តល់អាហារ។) ការកែតំរូវសំរាប់ ការឧបត្ថម្ភក្រៅផ្លូវការ គឺមានមូលដ្ឋាននៅលើ ថាតើជំនួយប៉ុន្មានដែលអ្នកមាន អាចដើម្បីជួយឲ្យជួបតាមសេចក្តីត្រូវការរបស់អ្នក។

យើងប្រើពាក្យដូចតទៅនេះនៅពេលពិភាក្សាពីការឧបត្ថម្ភក្រៅផ្លូវការ:

- **បានជួប:** នៅពេលការឧបត្ថម្ភក្រៅផ្លូវការជួបតាមគ្រប់សេចក្តីត្រូវការរបស់អ្នកសំរាប់ជួយជាមួយភារៈកិច្ច។ ឧទាហរណ៍ អ្នកមិនអាចចំអិនអាហារបាន ប៉ុន្តែកូនស្រីរបស់អ្នកចំអិនអាហារគ្រប់អាហារទាំងអស់ឲ្យអ្នកដោយ មិនមានបង់ប្រាក់។.

- **បានជួបមួយចំណែក:** នៅពេលការឧបត្ថម្ភក្រៅផ្លូវការជួបមួយភាគតាមសេចក្តីត្រូវការរបស់អ្នក សំរាប់ជួយដល់ ភារៈកិច្ច។ ឧទាហរណ៍ ដូចជាអ្នកមិនអាចចំអិនអាហារបាន ហើយអ្នកជិតខាងម្នាក់ ដែលមិនមានបង់ឈ្នួល, យកអាហារពេលល្ងាច 2 ដងក្នុងមួយអាទិត្យមកឲ្យអ្នក។.

  - បើសិនជាការឧបត្ថម្ភក្រៅផ្លូវការជួបមួយចំណែកនៃសេចក្តីត្រូវការរបស់អ្នក សំរាប់ជួយដល់ភារៈកិច្ចនោះយើងរកមើល ដើម្បីឲ្យដឹងថាតើញឹកញាប់យ៉ាងណាដែលអ្នកត្រូវការជំនួយ។ ពេលនោះយើងរកមើល ថាតើញឹកញាប់យ៉ាងណា ការឧបត្ថម្ភក្រៅផ្លូវការអាចមាន:

- តិចជាង ¼ នៃពេល។.
- ¼ ទៅ ½ នៃពេល។
- ½ ទៅ ¾ នៃពេល។
- លើសពី ¾ នៃពេលវេលា

- **មិនបានជួប:** គឺគ្មានជំនួយពីការឧបត្ថម្ភក្រៅផ្លូវការ។ ឧទាហរណ៍ អ្នកមិនអាចចំអិនអាហារដោយខ្លួនអ្នក និងគ្មានជនណាម្នាក់ ដែលនឹងចំអិនអាហារឲ្យអ្នក។

- **សកម្មភាពមិនបានកើតឡើង/អតិថិជនបានបដិសេធ:** អ្នកត្រូវការជំនួយជាមួយនឹង ADL ឬ IADL, ប៉ុន្តែអ្នក មិនចង់ឲ្យអ្នកមើលថែមានបង់ឈ្នួលរបស់អ្នក ឬជនណាម្នាក់ផ្សេងទៀតជួយធ្វើទេ។ ឧទាហរណ៍ មុនពេល ធ្វើការវាយតំលៃ កូនស្រីនៅក្រៅក្រុងរបស់អ្នកបានមកសួរសុខទុក្ខ និងបានជួយអ្នកនាំទៅបង្គន់។ ឥឡូវនេះនាងបាន ទៅវិញហើយ។ អ្នកមិនចង់ឲ្យមានជំនួយនាំទៅបង្គន់ ពីអ្នកមើលថែមានបង់ឈ្នួលរបស់អ្នក ឬជនណាម្នាក់ផ្សេងទៀតទេ។ *

- **សកម្មភាពមិនបានកើតឡើង/អតិថិជនមិនអាចធ្វើបាន: :** អ្នកមិនអាចធ្វើភារៈកិច្ច ADL ឬ IADL។ ឧទាហរណ៍ មនុស្សខ្វិនមិនអាចធ្វើភារៈកិច្ច ADL នៃការដើរនៅក្នុងបន្ទប់បាន។

- **សកម្មភាពមិនបានកើតឡើង/គ្មានអ្នកមើលថែ:** អ្នកត្រូវការជំនួយជាមួយ ADL ឬ IADL និងអាចយល់ព្រម ទទួលជំនួយ, ប៉ុន្តែភារៈកិច្ចមិនបានកើតឡើង ពីព្រោះអ្នកគ្មានអ្នកផ្តល់ការមើលថែដែលអាចមានដើម្បីជួយអ្នក។ ឧទាហរណ៍ អ្នកត្រូវការជំនួយក្នុងការនាំទៅងូតទឹកបីដងក្នុងមួយអាទិត្យ ប៉ុន្តែអ្នកមើលថែមិនអាចជួយអ្នកជាមួយ កិច្ចការនេះ ពីព្រោះគាត់ឈឺចង្កេះរបស់គាត់។*

* ចូរមើលការអធិប្បាយនៅក្នុងពិន្ទុសកម្មភាពនៃការរស់នៅប្រចាំថ្ងៃពីមុនទៅក្នុងចំណុចដោះស្រាយនេះ។

**ឧទាហរណ៍នានា:**

តារាងដែលបំពេញសំរាប់ ADLs/IADLs ដែលត្រូវសំរេចឲ្យមុនគេ គឺទៅខាងចុងនៃជំពូកការឧបត្ថម្ភក្រៅផ្លូវការ។ តារាងនោះផ្តល់ចំនួនភាគរយសំរាប់ ADLs/IADLs ដែលមានសិទ្ធិទទួលនិមួយៗ។

**ឧទាហរណ៍ #1:**

Ginny មានអាយុ 85 ឆ្នាំ។ គាត់រស់នៅតែឯង នៅអាគារមនុស្សចាស់។ គាត់ទទួលចំនួន 47 ម៉ោង "មូលដ្ឋាន "នៃសេវាមើលថែផ្ទាល់ខ្លួននៅតាមផ្ទះក្នុងមួយខែ។ Ginny ត្រូវការជំនួយក្នុងការស្លៀកពាក់, ផ្តល់ថ្នាំឲ្យគាត់ ទទួលទាន, ការងូតទឹក, អនាម័យផ្ទាល់ខ្លួន, ការដើរចុះឡើងនៅខាងក្រៅអាគាររបស់គាត់, រៀបចំអាហារ, ការងារក្នុងផ្ទះ, ការទៅទិញអីវ៉ាន់, និងនាំគាត់ទៅតាមការណាត់ជួបផ្នែកពេទ្យ។.

គ្រួសាររបស់ Ginny រៀបចំគ្រប់អាហារថ្ងៃត្រង់និងពេលល្ងាចទាំងអស់។ ពួកគេតែងតែមកឈប់និងរៀបចំ អាហារថ្ងៃត្រង់និងពេលល្ងាចសំរាប់គាត់។ ជួនកាលនៅពេលដែលពួកគេមិនបានមកឈប់, Ginny កំដៅម្ហូបខ្លះ ដែលពួកគេបានរៀបចំឲ្យគាត់ពីមុន និងទុកនៅក្នុងម៉ាស៊ីនត្រជាក់ឬទូរទឹកកក។ អ្នកមើលថែមានបង់ឈ្នួលរបស់ Ginny បានរៀបចំអាហារពេលព្រឹកឲ្យ Ginny ។

Ginny ទទួលជំនួយមកពីគ្រួសាររបស់គាត់ ដែលរៀបចំអាហារចំនួន 14 ពេលក្នុងចំណោម 21 ពេលដែលគាត់ពិសាររាល់ អាទិត្យ។ នេះគឺ 2/3 នៃអាហារដែល Ginny ទទួលទាន។ 2/3 គឺជាភាគបែងរវាង ½ - ¾ ។ សេចក្តីត្រូវការ របស់ Ginny សំរាប់ជំនួយរៀបចំអាហារគឺ "បានជួបមួយចំណែក " នៃពេលដោយគ្រួសារ របស់គាត់។

គ្រប់សេចក្តីត្រូវការរបស់ Ginny សំរាប់ជួយក្នុងការស្លៀកពាក់, ផ្តល់ថ្នាំឲ្យគាត់ទទួលទាន, ការងូតទឹក, អនាម័យផ្ទាល់ខ្លួន, ធ្វើការនៅផ្ទះ, ការទៅទិញអីវ៉ាន់, និងនាំគាត់ទៅតាមការណាត់ជួបផ្នែកពេទ្យគឺ "មិនបានជួប "។ ករណីនេះគឺ ពីព្រោះ Ginny មិនមានអ្នកណាម្នាក់ជួយគាត់ជាមួយរឿងទាំងអស់នេះ លើកលែងតែអ្នកមើលថែ មានបង់ឈ្នួលរបស់គាត់។

ម៉ោងមើលថែផ្ទាល់ខ្លួនរបស់ Ginny គឺបានកាត់បន្ថយចំនួន 3 ម៉ោងរៀងរាល់ខែ ពីព្រោះតែជំនួយពីគ្រួសារ របស់គាត់។ គាត់មិនត្រូវការជំនួយច្រើនហួសហេតុពីអ្នកមើលថែមានបង់ឈ្នួលរបស់គាត់ទេ។ ការគណនានោះគឺ បានពន្យល់នៅខាងក្រោម។ វាគឺជាមូលដ្ឋាននៃច្បាប់របស់ក្រសួង DSHS ។

សេចក្តីត្រូវការជំនួយរបស់ Ginny ផ្នែក ADLs និង IADLs ដែលត្រូវសំរេចឲ្យមុនគេ គឺបានបូកបញ្ចូលដំបូង។ មិនមែនគ្រប់តែ ADL គឺជា ADL ដែលត្រូវសំរេចឲ្យមុនគេនោះទេ។ Ginny ត្រូវការជំនួយ ជាមួយនឹង ADL ដែលត្រូវសំរេចឲ្យមុនគេ 4 ។ ទាំងនោះគឺការស្លៀកពាក់, ការផ្តល់ថ្នាំឲ្យគាត់ទទួលទាន, ការងូតទឹក, អនាម័យផ្ទាល់ខ្លួន។ សេចក្តីត្រូវការរបស់ Ginny សំរាប់ជំនួយជាមួយការដើរចុះឡើងនៅខាងក្រៅ អាគាររបស់គាត់គឺមិនមែនជា ADL ដែលត្រូវសំរេចឲ្យមុនគេទេ។

Ginny ត្រូវការជំនួយ ជាមួយនឹង ADL ដែលត្រូវសំរេចឲ្យមុនគេ 4 ។ ទាំងនោះគឺការរៀបចំអាហារ, ការងារក្នុងផ្ទះ, ការទៅទិញអីវ៉ាន់, និងនាំគាត់ទៅតាមការណាត់ជួបផ្នែកពេទ្យ។

ច្បាប់នៃក្រសួង DSHS កំណត់ឲ្យតំលៃភាគរយទៅជាចំនួននៃជំនួយ

Ginny អាចមានសំរាប់ ADL ឬ IADL និមួយៗដែលត្រូវសំរេចឲ្យបានមុនគេ។ តំលៃភាគរយ ពិនិត្យមើលចំពោះរបស់ពីរ:

- ទោះបីជាមានជំនួយការឧបត្ថម្ភក្រៅផ្លូវការណាមួយសំរាប់ ADL/IADL និមួយៗ ដែលត្រូវសំរេចឲ្យមុនគេ; និង

- តើមានជំនួយប៉ុន្មាន បើសិនជាមានណាមួយ។

នេះគឺជាតារាងអំពីតែ Ginny និង ADLs/IADLs ដែលត្រូវសំរេចឲ្យមុនគេរបស់គាត់។ Ginny មានជំនួយមួយចំណែក ឬជំនួយអាចមានសំរាប់ការរៀបចំអាហារពីគ្រួសាររបស់គាត់។ Ginny មិនមានជំនួយណាមួយ ឬអាចមានជំនួយ (លើកលែងតែមកអ្នកផ្តល់ការមើលថែដែលបានបង់ប្រាក់របស់គាត់) សំរាប់អ្វីៗផ្សេងទៀត។

នៅក្នុងតារាងខាងក្រោម ហេតុអ្វីបានជាពាក្យ "n/a" (មិនអាចអនុវត្ត) បានចុះសំរាប់ជំនួយដែលអាចមាន សំរាប់អ្វីៗទាំងអស់ ជាជាងពាក្យ "រៀបចំអាហារ"? ពីព្រោះជំនួយដែលអាចមានគឺត្រូវបានចុះប៉ុណ្ណោះ **បើ**អាចមានជំនួយមួយចំណែកសំរាប់ ADL/IADL ។ N/A (មិនអាចអនុវត្ត)ត្រូវបានចុះនៅពេល:

- គឺគ្មានជំនួយអាចមានសំរាប់ជួយ (មិនជួបតាម);
- ជំនួយទាំងអស់គឺអាចមានទទួល (ជួបតាម);
- ADL/IADL មិនបានកើតឡើងទេ ពីព្រោះអ្នកមិនអាច ឬអ្នកមិនមានអ្នកផ្តល់ការបំរើ;
- ADL/IADL មិនបានកើតឡើងទេ ពីព្រោះអ្នកបានបដិសេធជំនួយសំរាប់ឲ្យជួយ។

| ADLs/IADLs | ស្ថានភាព | ជំនួយដែលអាចមាន | តំលៃភាគរយ |
|---|---|---|---|
| ការស្លៀកពាក់ | មិនបានជួប | N/A (មិនអាចអនុវត្ត) | 1 |
| ជំនួយជាមួយថ្នាំពេទ្យ | មិនបានជួប | N/A (មិនអាចអនុវត្ត) | 1 |
| ការងូតទឹក | មិនបានជួប | N/A (មិនអាចអនុវត្ត) | 1 |
| អនាម័យផ្ទាល់ខ្លួន | មិនបានជួប | N/A (មិនអាចអនុវត្ត) | 1 |
| ការរៀបចំអាហារ | បានជួបមួយចំណែក | ¼ ទៅ ½ នៃពេល។ | .1 |
| ការងារក្នុងផ្ទះ | មិនបានជួប | N/A (មិនអាចអនុវត្ត) | 1 |
| ការទៅទិញអីវ៉ាន់ | មិនបានជួប | N/A (មិនអាចអនុវត្ត) | 1 |
| ការធ្វើដំណើរតាមការណាត់ជួបពេទ្យ | មិនបានជួប | N/A (មិនអាចអនុវត្ត) | 1 |

សរុបចំនួនតំលៃភាគរយ = 7.1

ចំនួនសរុបនៃ ADLs/IADLs ដែលត្រូវសំរេចឲ្យមុនគេ = 8

វិធានការទី 1 និង ទី 2 គឺបូកបញ្ចូលទៅនឹងចំនួនសរុបនៃចំនួនភាគរយ និងចំនួនសរុបនៃ ADLs/IADLs ដែលត្រូវសំរេចឲ្យមុនគេថ។ ចូរមើលខាងលើ។

វិធានការទី 3 គឺចែកចំនួនសរុបនៃចំនួនភាគរយ ជាមួយនឹងចំនួននៃ ADLs/IADLs ដែលមានសិទ្ធិទទួល។ ចំនួននេះគឺចំនួន A ។ 7.1 ÷ 8 = .8875 = ចំនួន A ។ ចំនួននេះគឺតំឡើងខ្ពង់ទៅ .89 ។

វិធានការទី 4 គឺដកចំនួន A ពី 1 ។  1 – .89 = 0.11 ។ ចំនួននេះគឺចំនួន B ។

វិធានការទី  5  គឺចែកចំនួន B នឹង 3 ។  11 ÷ 3 = .036 ។ ចំនួននេះគឺចំនួន C ។

ចំនួននេះគឺតំឡើងខ្ទង់ទៅ .04 ។

វិធានការទី  6  គឺបូកចំនួន A ទៅនឹងចំនួន C ។  .89 + .04 = .93 ។ ចំនួននេះគឺចំនួន D ។

វិធានការទី  7  គឺគុណចំនួន D ទៅនឹងមូលដ្ឋានម៉ោងរបស់  Ginny (ដែលមានចំនួន 47). 47 x .93 = 43.71 ។ ចំនួននេះគឺតំឡើងខ្ទង់ទៅ 44 ។ នេះគឺជាចំនួនម៉ោងនៃការមើលថែផ្ទាល់ខ្លួន ដែល Ginny នឹងទទួលក្នុងខែនិមួយៗ។

មូលដ្ឋានម៉ោងរបស់  Ginny នឹងត្រូវបន្ថយ 3 ម៉ោងក្នុងមួយខែ ពីព្រោះគ្រួសាររបស់គាត់រៀបចំអាហារពេល ថ្ងៃត្រង់និងពេលល្ងាចរបស់គាត់។ ( 47 - 44 = 3 ម៉ោងតិចជាងមុនក្នុងមួយខែ)។

**ឧទាហរណ៍ #2:**

Sam មានអាយុ 37 ឆ្នាំ។ គាត់គឺជាមនុស្សខ្វិនដៃជើងទាំងអស់, ប្រើកៅអីកង់, និងរស់នៅជាមួយដៃគូក្នុងផ្ទះ, ឈ្មោះ John ។ John ធ្វើការនៅខាងក្រៅឆ្ងាយពីផ្ទះ។ Sam ត្រូវការជំនួយជាមួយនឹងការប្រែខ្លួនក្នុងគ្រែ, ការផ្លាស់ប្តូរកន្លែង, ការប្រើប្រាស់បង្គន់, ការស្លៀកពាក់, អនាម័យផ្ទាល់ខ្លួន, ការងូតទឹក, ការរៀបចំអាហារ, ការងារក្នុងផ្ទះ, និងការទៅទិញអីវ៉ាន់។ ពីព្រោះគាត់គឺជាមនុស្សខ្វិនដៃជើងទាំងអស់ គាត់មិនអាចដើរបាន។ Sam ទទួលបាន "មូលដ្ឋាន" ម៉ោងមើលថែ 327 ម៉ោងនៃសេវាមើលថែផ្ទាល់ខ្លួននៅតាមផ្ទះក្នុងមួយខែ។.

John រៀបចំអាហារពេលព្រឹកឲ្យ Sam និងអាហារថ្ងៃត្រង់នៅថ្ងៃសៅរ៍និងថ្ងៃអាទិត្យ។  John រៀបចំអាហារពេលល្ងាចឲ្យ Sam ចំនួន 3 ដងក្នុងថ្ងៃអាទិត្យ។ អ្នកផ្តល់ការមើលថែរបស់ Sam រៀបចំអាហារពេលព្រឹកនិងអាហារថ្ងៃត្រង់នៅថ្ងៃធ្វើការក្នុងអាទិត្យ។  John ធ្វើការ 4 យប់ផ្សេងទៀត ដូច្នេះអ្នកផ្តល់ការមើលថែមានឈ្នួលរបស់ Sam រៀបចំអាហារពេលល្ងាចឲ្យ Sam នៅយប់ទាំងអស់នោះ។

Sam ទទួលជំនួយមកពី John ដែលរៀបចំអាហារចំនួន 7 នៃ 21ពេលដែលគាត់ពិសាររាល់អាទិត្យ។ នេះគឺ 1/3 នៃអាហារដែលបានរៀបចំសំរាប់ Sam ។ 1/3 គឺជាភាគបែងរវាង ¼ - ½ ។ សេចក្តីត្រូវការរបស់ Sam សំរាប់ជំនួយរៀបចំអាហារគឺ "បានជួបមួយចំណែក" នៃពេលដោយ John ¼ - ½ នៃពេល។

John ទៅទិញអីវ៉ាន់និងធ្វើការងារក្នុងផ្ទះឲ្យ Sam ទាំងអស់។ សេចក្តីត្រូវការរបស់ Sam សំរាប់ជួយ ការងារនៅផ្ទះនិងការទៅទិញអីវ៉ាន់គឺ "បានជួប"។

គ្រប់សេចក្តីត្រូវការរបស់ Sam សំរាប់ជួយក្នុងការប្រែខ្លួនក្នុងគ្រែ, ការផ្លាស់ប្តូរកន្លែង, ការបើប្រាស់បង្គន់, ការស្លៀកពាក់, អនាម័យផ្ទាល់ខ្លួន, ការងូតទឹកគឺ "មិនបានជួប"។ នេះគឺពីព្រោះតែ Sam មិនមានអ្នកណាម្នាក់ ដើម្បីជួយគាត់ជាមួយនឹងអំពើទាំងនេះ លើកលែងតែអ្នកមើលថែមានបង់ឈ្នួលរបស់គាត់។

ម៉ោងមើលថែផ្ទាល់ខ្លួនរបស់ Sam គឺបានកាត់បន្ថយចំនួន 62 ម៉ោងក្នុងមួយខែ។ ពីព្រោះតែជំនួយរបស់ John, Sam មិនត្រូវការជំនួយយ៉ាងច្រើនបំផុតពីអ្នកមើលថែមានបង់ឈ្នួលរបស់គាត់ទេ។ ការគណនានោះគឺ បានពន្យល់នៅខាងក្រោម។ វាគឺជាមូលដ្ឋាននៃច្បាប់របស់ក្រសួង DSHS ។

សេចក្តីត្រូវការជំនួយរបស់ Sam ផ្អែក ADLs និង IADLs ដែលត្រូវសំរេចឲ្យមុនគេ គឺបានបូកបញ្ចូលដំបូង។ មិនមែនគ្រប់តែ ADL គឺជា ADL ដែលមានសិទ្ធិទទួលទេ។ Sam ត្រូវការជំនួយ ជាមួយនឹង ADL ដែលមានសិទ្ធិទទួល 7 ។ ទាំងនោះគឺការប្រែខ្លួនក្នុងគ្រែ, ការផ្លាស់ប្តូរកន្លែង, ការបើប្រាស់បង្គន់, ការស្លៀកពាក់, អនាម័យផ្ទាល់ខ្លួន, ការងូតទឹក។

Sam ត្រូវការជំនួយជាមួយនឹង IADLs ដែលត្រូវសំរេចឲ្យមុនគេ 3 ។ ទាំងនោះគឺការរៀបចំអាហារ, ការងារក្នុងផ្ទះ, និងការទៅទិញអីវ៉ាន់។

ច្បាប់នៃក្រសួង DSHS កំណត់ឲ្យតំលៃភាគរយទៅជាចំនួននៃជំនួយ

Sam មានសំរាប់ ADL ឬ IADL និមួយៗ ដែលត្រូវសំរេចឲ្យបានមុនគេ។ តំលៃភាគរយ ពិនិត្យមើលចំពោះរបស់ពីរ:

- ទោះបីជាមានជំនួយការឧបត្ថម្ភក្រៅផ្លូវការណាមួយសំរាប់ ADL/IADL និមួយៗ ដែលត្រូវសំរេចឲ្យមុនគេ; និង
- តើមានជំនួយប៉ុន្មាន បើសិនជាមានណាមួយ។

នេះគឺជាតារាងអំពីតែ Sam និង ADLs/IADLs ដែលត្រូវសំរេចឲ្យមុនគេរបស់គាត់។ Sam មានជំនួយមួយចំណែក ឬជំនួយអាចមានសំរាប់ការរៀបចំអាហារ។ គាត់មានជំនួយទាំងអស់ ឬជំនួយសំរាប់ការទៅទិញអីវ៉ាន់ និង ការងារក្នុងផ្ទះ។ Sam មិនមានជំនួយណាមួយ ឬជំនួយអាចមាន (លើកលែងតែមកអ្នកផ្តល់ការមើលថែ ដែលបានបង់ប្រាក់របស់គាត់) សំរាប់កិច្ចការដទៃទៀត។

ជំនួយដែលអាចមានសំរាប់អ្វីៗទាំងអស់ ប៉ុន្តែការរៀបចំអាហារ គឺត្រូវសរសេរចុះ n/a (មិនអាចអនុវត្តបាន)។ នៅក្នុងតារាងខាងក្រោម ហេតុអ្វីពាក្យ "n/a" ត្រូវបានសរសេរចុះសំរាប់អ្វីៗទាំងអស់ផ្សេងទៀត? N/A ត្រូវសរសេរចុះនៅពេល:

- គឺគ្មានជំនួយអាចមានសំរាប់ជួយ (មិនជួបតាម);
- ជំនួយទាំងអស់គឺអាចមានទទួល (ជួបតាម);
- ADL/IADL មិនបានកើតឡើងទេ ពីព្រោះអ្នកមិនអាច ឬអ្នកមិនមានអ្នកផ្តល់ការបំរើ;
- ADL/IADL មិនបានកើតឡើងទេ ពីព្រោះអ្នកបានបដិសេធជំនួយសំរាប់ឲ្យជួយ។

| ADLs/IADLs | ស្ថានភាព | ជំនួយដែលអាចមាន | តំលៃភាគរយ |
|---|---|---|---|
| គ្រែចល័ត | មិនបានជួប | N/A (មិនអាចអនុវត្ត) | 1 |
| ការផ្ទេរ | មិនបានជួប | N/A (មិនអាចអនុវត្ត) | 1 |
| ដើរក្នុងបន្ទប់ | មិនបានកើតឡើង | N/A (មិនអាចអនុវត្ត) | 1 |
| ការប្រើប្រាស់បង្គន់ | មិនបានជួប | N/A (មិនអាចអនុវត្ត) | 1 |
| ការស្លៀកពាក់ | មិនបានជួប | N/A (មិនអាចអនុវត្ត) | 1 |
| អនាម័យផ្ទាល់ខ្លួន | មិនបានជួប | N/A (មិនអាចអនុវត្ត) | 1 |
| ការងូតទឹក | មិនបានជួប | N/A (មិនអាចអនុវត្ត) | 1 |
| ការរៀបចំអាហារ | បានជួបមួយចំណែក | ¼ - ½ | .2 |
| ការទៅទិញអីវ៉ាន់ | បានដល់លក្ខណសម្បត្តិ | N/A (មិនអាចអនុវត្ត) | 0 |
| ការងារក្នុងផ្ទះ | បានដល់លក្ខណសម្បត្តិ | N/A (មិនអាចអនុវត្ត) | 0 |

សរុបចំនួនតំលៃភាគរយ = 7.2

ចំនួនសរុបនៃ ADLs/IADLs ដែលត្រូវសំរេចឲ្យមុនគេ = 10

វិធានការទី 1 និង ទី 2 គឺបូកបញ្ចូលទៅនឹងចំនួនសរុបនៃចំនួនភាគរយ និងចំនួនសរុបនៃ ADLs/IADLs ដែលត្រូវសំរេចឲ្យមុនគេ។ ចូរមើលខាងលើ។

វិធានការទី 3 គឺចែកចំនួនសរុបនៃចំនួនភាគរយ ជាមួយនឹងចំនួននៃ ADLs/IADLs ដែលត្រូវសំរេចឲ្យមុនគេ។ ចំនួននេះគឺចំនួន A ។ 7.2 ÷ 10 = .72 = ចំនួន A ។

វិធានការទី 4 គឺដកចំនួន A ពី 1 ។ 1 - .72 = .28 ។ ចំនួននេះគឺចំនួន B ។

វិធានការទី 5 គឺចែកចំនួន B នឹង 3 ។ .28 ÷ 3 = .093 ។ ចំនួននេះគឺចំនួន C ។
ចំនួននេះគឺតំឡើងខ្ពង់ទៅ .09 ។

វិធានការទី 6 គឺបូកចំនួន A ទៅនឹងចំនួន C ។ .72 + .09 =. 81 ។ ចំនួននេះគឺចំនួន D ។

វិធានការទី 7 គឺគុណចំនួន D ទៅនឹងមូលដ្ឋានម៉ោ 265 ។ នេះគឺជាចំនួនម៉ោងនៃការមើលថែផ្ទាល់ខ្លួន ដែល Sam នឹងទទួលក្នុងខែនិមួយៗ។

មូលដ្ឋានម៉ោងរបស់ Sam នឹងត្រូវកាត់បន្ថយ 62 ម៉ោងក្នុងមួយខែ ពីព្រោះ John រៀបចំអាហារខ្លះ និងធ្វើការងារក្នុងផ្ទះទាំងអស់និងទៅទិញអីវ៉ាន់។ (327 - 265 = 62 ម៉ោងតិចជាងមុនក្នុងមួយខែ)។

**ឧទាហរណ៍ #3:**

Bob មានអាយុ 75 ឆ្នាំ។ គាត់រស់នៅតែម្នាក់ឯង ក្នុងផ្ទះបង្កើតផលលើដីមួយចំនួនធំ។ Bob ត្រូវការជំនួយក្នុង ការស្លៀកពាក់, អនាម័យផ្ទាល់ខ្លួន, ការងូតទឹក, ការដាំស្ល, ការងារក្នុងផ្ទះ, និងការទៅទិញអីវ៉ាន់។ Bob ទទួលបាន 69 ម៉ោង "មូលដ្ឋាន "នៃសេវាមើលថែផ្ទាល់ខ្លួននៅតាមផ្ទះក្នុងមួយខែ។.

កូនរបស់ Bob, ឈ្មោះ Joe , មកសួរសុខទុក្ខគាត់នៅគ្រប់ចុងសប្តាហ៍។ គាត់មកដល់នៅមុនពេលដែល Bob ទៅគេងនៅថ្ងៃសុក្រ និងចេញទៅវិញនៅថ្ងៃអាទិត្យពេលរសៀល។ Joe រៀបចំអាហារឲ្យ Bob ទាំងអស់នៅ ថ្ងៃសៅរ៍និងអាហារពីរពេលទៀតនៅថ្ងៃអាទិត្យ។ អ្នកមើលថែមានបង់ឈ្នួលរបស់ Bob រៀបចំអាហារដែលនៅ សល់ក្នុងអាទិត្យឲ្យ Bob ។

Bob ទទួលជំនួយពី Joe ដែលរៀបចំអាហារពី 5 ទៅ 21 ពេលឲ្យ Bob ទទួលទានរៀងរាល់អាទិត្យ។ នេះគឺតិចជាង ¼ នៃអាហារដែលបានរៀបចំសំរាប់ Bob ។ តិចជាង ¼ នៃពេលគឺជាភាគបែងរវាង 0 -1/4 ។ ជំនួយត្រូវការរបស់ Bob សំរាប់រៀបចំអាហារគឺ "បានជួបមួយភាគ " ដោយតិចជាង ¼ នៃពេលរបស់ Joe ។

Joe ជួយ Bob ក្នុងការស្លៀកពាក់សំលៀកបំពាក់សំរាប់គេងនៅយប់ថ្ងៃសុក្រនិងថ្ងៃសៅរ៍ និងជួយស្លៀកពាក់ នៅព្រឹកថ្ងៃសៅរ៍និងថ្ងៃអាទិត្យ។ Bob ត្រូវការជំនួយស្លៀកពាក់ 14 ដងនៅក្នុងអាទិត្យ។ Joe ជួយ Bob ក្នុងពេលទាំងនោះ ដែលមានចំនួនច្រើនជាង ¼ នៃពេលបន្តិច។ ចំនួនច្រើនជាង ¼ បន្តិចនៃពេល គឺជាភាគបែងរវាង ¼ - ½ ។ Bob ត្រូវការជំនួយស្លៀកពាក់គឺជា "បានជួបមួយភាគ " ដោយ ¼ ទៅ ½ នៃពេលរបស់ Joe ។

គ្រប់សេចក្តីត្រូវការរបស់ Bob សំរាប់ជួយផ្នែកអនាម័យផ្ទាល់ខ្លួន, ធ្វើកិច្ចការនៅផ្ទះ, និងការទៅទិញអីវ៉ាន់គឺ "មិនបានជួប "។ នេះគឺពីព្រោះ Bob មិនមានជនណាម្នាក់ជួយគាត់ជាមួយនឹងរឿងទាំងនេះទេ លើកលែងតែ អ្នកមើលថែមានបង់ឈ្នួលរបស់គាត់។ ទោះបីយ៉ាងណាក៏ដោយ Bob ត្រូវការជំនួយក្នុងការងូតទឹក គាត់មិនទទួលយកពីអ្នកមើលថែមានបង់ឈ្នួលរបស់គាត់, ពី Joe ឬជនណាម្នាក់ផ្សេងទៀតទេ។

ម៉ោងមើលថែផ្ទាល់របស់ Bob គឺបានកាត់បន្ថយចំនួន 10 ម៉ោងរាល់ខែ ពីព្រោះដោយសារជំនួយរបស់ Joe និងពីព្រោះ Bob មិនទទួលយកជំនួយក្នុងការងូតទឹកទេ។ ការគណនានោះគឺបានពន្យល់នៅខាងក្រោម។ គឺមាន មូលដ្ឋានលើច្បាប់របស់ក្រសួង DSHS ។

សេចក្តីត្រូវការជំនួយរបស់ Bob ផ្នែក ADLs និង IADLs ដែលត្រូវសំរេចឲ្យមុនគេនោះ គឺត្រូវបានបូកចូលដំបូង។ មិនមែនគ្រប់តែ ADL គឺជា ADL ដែលត្រូវសំរេចឲ្យមុនគេនោះទេ។ Bob ត្រូវការជំនួយជាមួយ ADLs ចំនួន 3 ។ ទាំងនោះគឺ ការស្លៀកពាក់, អនាម័យផ្ទាល់ខ្លួន, និងការងូតទឹក។ ប៉ុន្តែ Bob ដោយសារតែ នឹងព្រមទទួលយកជំនួយក្នុងការងូតទឹក, គឺមិនអាចរាប់ថាមានសិទ្ធិសំរាប់ ADL ទេ។ Bob មានសិទ្ធិទទួល ADLs ចំនួន 2 ដែលត្រូវបានរាប់។

Bob ត្រូវការជំនួយ IADLs ដែលត្រូវសំរេចឲ្យមុនគេនោះ 3 ។ ជំនួយនោះគឺការរៀបចំអាហារ, ធ្វើការងារនៅផ្ទះ, និងការទៅទិញអីវ៉ាន់។

ច្បាប់នៃក្រសួង DSHS កំណត់ឲ្យតំលៃភាគរយទៅជាចំនួននៃជំនួយ

Bob អាចមានសំរាប់ ADL ឬ IADL និមួយៗដែលត្រូវសំរេចឲ្យបានមុនគេ។  តំលៃភាគរយ ពិនិត្យមើល ចំពោះរបស់ 2 :

- ទោះបីជាមានជំនួយការឧបត្ថម្ភក្រៅផ្លូវការណាមួយសំរាប់ ADL/IADL និមួយៗ ដែលត្រូវសំរេចឲ្យមុនគេ; និង
- តើមានជំនួយប៉ុន្មាន បើសិនជាមានណាមួយ។

នេះគឺជាតារាងអំពីតែ Bob និង ADLs/IADLs ដែលត្រូវសំរេចឲ្យមុនគេរបស់គាត់។  Bob មានជំនួយមួយចំណែក ឬជំនួយអាចមានសំរាប់ការរៀបចំអាហារនិងការស្លៀកពាក់។

ជំនួយដែលអាចមានសំរាប់អ្វីៗទាំងអស់ ប៉ុន្តែការរៀបចំអាហារ និងការស្លៀកពាក់ គឺត្រូវសរសេរចុះ n/a (មិនអាចអនុវត្តបាន)។  នៅក្នុងតារាងខាងក្រោម ហេតុអ្វីពាក្យ “n/a” ត្រូវបានសរសេរចុះសំរាប់ អនាម័យផ្ទាល់ខ្លួន, ការទៅទិញអីវ៉ាន់, ការងារក្នុងផ្ទះ, និងការងូតទឹក? N/A ត្រូវសរសេរចុះនៅពេល:

- គឺគ្មានជំនួយអាចមានសំរាប់ជួយ (មិនជួបតាម);
- ជំនួយទាំងអស់គឺអាចមានទទួល (ជួបតាម);
- ADL/IADL មិនបានកើតឡើងទេ ពីព្រោះអ្នកមិនអាច ឬអ្នកមិនមានអ្នកផ្តល់ការបំរើ;
- ADL/IADL មិនបានកើតឡើងទេ ពីព្រោះអ្នកបានបដិសេធជំនួយសំរាប់ឲ្យជួយ។

| ADLs/IADLs | ស្ថានភាព | ជំនួយដែលអាចមាន | តំលៃភាគរយ |
|---|---|---|---|
| ការស្លៀកពាក់ | បានជួបមួយចំណែក | ¼ - ½ | .55 |
| អនាម័យផ្ទាល់ខ្លួន | មិនបានជួប | N/A (មិនអាចអនុវត្ត) | 1 |
| ការងូតទឹក (មិនបានរាប់ទេ) | បដិសេធ | N/A (មិនអាចអនុវត្ត) | 0 |
| ការរៀបចំអាហារ | បានជួបមួយចំណែក | តិចជាង ¼ | .3 |
| ការទៅទិញអីវ៉ាន់ | មិនបានជួប | N/A (មិនអាចអនុវត្ត) | 1 |
| ការងារក្នុងផ្ទះ | មិនបានជួប | N/A (មិនអាចអនុវត្ត) | 1 |

សរុបចំនួនតំលៃភាគរយ =   3.85

ចំនួនសរុបនៃ ADLs/IADLs ដែលត្រូវសំរេចឲ្យមុនគេ = 5

វិធានការទី 1  និង ទី 2  គឺបូកបញ្ចូលទៅនឹងចំនួនសរុបនៃចំនួនភាគរយ និងចំនួនសរុបនៃ ADLs/IADLs ដែលត្រូវសំរេចឲ្យមុនគេ។ ចូរមើលខាងលើ។

វិធានការទី 3  គឺចែកចំនួនសរុបនៃចំនួនភាគរយ ជាមួយនឹងចំនួននៃ ADLs/IADLs ដែលត្រូវសំរេចឲ្យមុនគេ។  ចំនួននេះគឺចំនួន  A ។   3.85 ÷ 5 = .77 ។

វិធានការទី 4 គឺដកចំនួន A ពី 1 ។   1 - .77 = .23 ។  ចំនួននេះគឺចំនួន B ។

វិធានការទី 5 គឺចែកចំនួន B នឹង 3 ។ .23 ÷ 3 = .07666 ដែលចំនួននេះគឺតំឡើងខ្ពង់ទៅ .08 ។ ចំនួននេះគឺចំនួន C ។

វិធានការទី 6 គឺបូកចំនួន A ទៅនឹងចំនួន C ។ .77 + .08 = .85 ។ ចំនួននេះគឺចំនួន D ។

វិធានការទី 7 គឺគុណចំនួន D ទៅនឹងមូលដ្ឋានម៉ោងរបស់ Bob (ដែលមានចំនួន 69) ។ 69 x 0.85 = 58.65 ។ ចំនួននេះគឺតំឡើងខ្ពង់ទៅ 59 ។ នេះគឺជាចំនួនម៉ោងនៃការមើលថែផ្ទាល់ខ្លួន ដែល Bob នឹងទទួលក្នុងខែនិមួយៗ។

មូលដ្ឋានម៉ោងរបស់ Bob នឹងត្រូវកាត់បន្ថយ 10 ម៉ោងក្នុងមួយខែ ពីព្រោះ Joe រៀបចំអាហារពេល ចុងសប្តាហ៍ស្ទើរតែទាំងអស់, ជួយ Bob ជាមួយការស្លៀកពាក់នៅចុងសប្តាហ៍ និងពីព្រោះ Bob បដិសេធ ជំនួយជាមួយការងូតទឹក ។ (69 - 59 = 10 ម៉ោងតិចជាងមុនក្នុងមួយខែ)។

**ឧទាហរណ៍ #4:**

Janet រស់នៅជាមួយប្តីរបស់គាត់ ឈ្មោះ Bill ។ Janet មានអាយុ 63 ឆ្នាំ។ គាត់នៅធ្វើការនៅឡើយ ប៉ុន្តែធ្វើតែពាក់កណ្តាលពេលប៉ុណ្ណោះ។ មានជំងឺសរសៃប្រសាទច្រើនយ៉ាង។ គាត់ទទួលបាន "មូលដ្ឋាន " ម៉ោងមើលថែ 115 ម៉ោងនៃសេវាមើលថែផ្ទាល់ខ្លួននៅតាមផ្ទះក្នុងមួយខែ។ Janet ត្រូវការជំនួយក្នុង ការស្លៀកពាក់, ការងូតទឹក, អនាម័យផ្ទាល់ខ្លួន, ការផ្លាស់ប្តូរកន្លែង, ការដើរចុះឡើងនៅខាងក្រៅផ្ទះរបស់គាត់, ការរៀបចំអាហារ, ការងារក្នុងផ្ទះ, ការទៅទិញអីវ៉ាន់, និងនាំគាត់ទៅតាមការណាត់ជួបផ្នែកពេទ្យ។ .

Bill រៀបចំអាហារសំរាប់ខ្លួនគាត់និង Janet រៀងរាល់យប់។ គាត់ក៏រៀបចំអាហារពេលព្រឹកសំរាប់ Janet និងអាហារថ្ងៃត្រង់នៅពេលចុងអាទិត្យ។ អ្នកមើលថែមានប្រាក់ឈ្នួលរបស់ Janet រៀបចំអាហារពេលព្រឹក និងអាហារថ្ងៃត្រង់ឲ្យគាត់នៅក្នុងអាទិត្យ។

Janet ទទួលជំនួយពី Bill សំរាប់អាហារ 11 ដងក្នុងចំណោម 21 ដង ដែលគាត់បរិភោគរៀងរាល់អាទិត្យ។ នេះគឺមានចំនួនលើសពី ½ បន្តិចនៃការរៀបចំអាហារសំរាប់ Janet ។ ចំនួនច្រើនជាង ½ បន្តិច គឺ a c រវាង ½ - ¾ ។ សេចក្តីត្រូវការរបស់ Janet សំរាប់ជំនួយដើម្បីជួយការរៀបចំអាហារ គឺ "បានជួបមួយចំណែក" ដោយ ½ - ¾ នៃពេលរបស់ Bill ។

Bill ជួយ Janet ឲ្យប្តូរអាវគេងរបស់គាត់រៀងរាល់យប់។ អ្នកមើលថែមានប្រាក់ឈ្នួលរបស់ Janet ជួយស្លៀក ពាក់ឲ្យ Janet នៅពេលព្រឹក។ Janet ត្រូវការជំនួយក្នុងការស្លៀកពាក់ 14 ពេលក្នុងអាទិត្យ។ Bill ជួយ Janet ក្នុងការស្លៀកពាក់ ½ ពេល។ ½ ពេលគឺជាភាគបែងរវាង ½ - ¾ ។ សេចក្តីត្រូវការរបស់ Janet សំរាប់ជំនួយក្នុងការស្លៀកពាក់គឺ "បានជួបមួយចំណែក" ដោយ ½ - ¾ នៃពេលរបស់ Bill ។

Bill ជួយ Janet ឲ្យក្រោកពីសូហ្វារៀងរាល់យប់នៅក្រោយពេលដែលពួកគេមើល TV ។ អ្នកមើលថែ មានប្រាក់ឈ្នួលរបស់ Janet ជួយ Janet ឲ្យក្រោកចេញពីគ្រែនៅពេលព្រឹកក្នុងអាទិត្យ។ អ្នកមើលថែ មានប្រាក់ឈ្នួលរបស់ Janet ក៏ជួយ Janet ឲ្យក្រោកពីសូហ្វានៃថ្ងៃធ្វើការក្នុងអាទិត្យ។ Bill ជួយ Janet ឲ្យក្រោកចេញពីគ្រែនិងពីសូហ្វានៅថ្ងៃនៃចុងអាទិត្យ។ Janet ត្រូវការជំនួយក្នុងការក្រោកចេញពីគ្រែ ឬក្រោកចេញពីសូហ្វា 21 ដងក្នុងមួយអាទិត្យ។ ជួយក្នុងការក្រោកចេញពីគ្រែ ឬចេញពីសូហ្វាគឺជាការផ្លាស់ប្តូរ។ Bill ជួយ Janet ធ្វើការផ្លាស់ប្តូរចំនួន 11 ដង ក្នុង 21 ដង ដែលគឺច្រើនជាង ½ ពេលបន្តិចដែល Janet ត្រូវការជំនួយ។ ច្រើនជាង ½ បន្តិចគឺជាភាគបែងចន្លោះ ½ - ¾ ។ សេចក្តីត្រូវការរបស់ Janet សំរាប់ ជំនួយជាមួយការផ្លាស់ប្តូរគឺ "បានជួបមួយចំណែក" ដោយ ½ - ¾ នៃពេលរបស់ Bill ។

Bill ធ្វើការងារក្នុងផ្ទះ និងការទៅទិញអីវ៉ាន់សំរាប់ទាំងពីរនាក់។  សេចក្តីត្រូវការរបស់ Janet សំរាប់ជំនួយគឺ "បានជួប" សំរាប់ការងារក្នុងផ្ទះ និងការទៅទិញអីវ៉ាន់។

អ្នកមើលថែមានប្រាក់ឈ្នួលរបស់ Janet ផ្តល់គ្រប់ជំនួយដែល Janet ត្រូវការក្នុងការងូតទឹក, អនាម័យផ្ទាល់ខ្លួន, និងនាំគាត់ទៅតាមការណាត់ជួបផ្នែកពេទ្យ។  Janet តាមធម្មតាងូតទឹក 3 ដងក្នុងមួយអាទិត្យ។  Janet ទៅជួបវេជ្ជបណ្ឌិតរបស់គាត់ យ៉ាងហោចណាស់ម្តងក្នុងមួយខែ និងជាញឹកញាប់ ពីរដងក្នុងមួយខែ។  ដោយបន្ថែមលើនេះ គាត់អញ្ជើញទៅព្យាបាលកាយសម្បទាម្តងក្នុងមួយអាទិត្យ។ អ្នកមើលថែមានប្រាក់ឈ្នួលរបស់គាត់ ជូនគាត់ទៅគ្រប់ការណាត់ជួបទាំងអស់នេះ។  សេចក្តីត្រូវការជំនួយរបស់ Janet ជាមួយការងូតទឹក, អនាម័យផ្ទាល់ខ្លួន, និងនាំគាត់ទៅតាមការណាត់ជួបផ្នែកពេទ្យគឺ "មិនបានជួប"។

អ្នកមើលថែមានប្រាក់ឈ្នួលរបស់ Janet ក៏ជួយ Janet ឲ្យដើរចេញក្រៅមានសុវត្ថិភាពទៅប្រអប់សំបុត្រ នៅក្នុងអាទិត្យ។

ម៉ោងមើលថែផ្ទាល់ខ្លួនរបស់ Janet គឺកាត់បន្ថយចុះ 39 ម៉ោង។  ដោយសារតែជំនួយរបស់ Bill, Janet មិនត្រូវការជំនួយយ៉ាងច្រើនមកពីអ្នកមើលថែមានប្រាក់ឈ្នួលរបស់គាត់ទេ។  ការគណនានេះគឺបានពន្យល់នៅ ខាងក្រោម។

សេចក្តីត្រូវការជំនួយរបស់ Janet ផ្នែក ADLs និង IADLs ដែលត្រូវសំរេចឲ្យមុនគេ គឺបានបូកបញ្ចូលដំបូង។  មិនមែនគ្រប់តែ ADL គឺជា ADL ដែលមានសិទ្ធិទទួលទេ។  Janet ត្រូវការជំនួយជាមួយនឹង ADL ដែលត្រូវសំរេចឲ្យមុនគេ  4 ។  ទាំងនោះគឺការស្លៀកពាក់, ការងូតទឹក, អនាម័យផ្ទាល់ខ្លួន, និងការផ្លាស់ប្តូរ។  សេចក្តីត្រូវការរបស់ Janet សំរាប់ជំនួយជាមួយការដើរចុះឡើងនៅខាងក្រៅផ្ទះរបស់គាត់ គឺមិនមែនជា ADL ដែលមានសិទ្ធិទទួលទេ។  .

Janet ត្រូវការជំនួយជាមួយនឹង IADLs ដែលត្រូវសំរេចឲ្យមុនគេ  4 ។  ទាំងនោះគឺការរៀបចំអាហារ, ការងារក្នុងផ្ទះ, ការដើរទិញអីវ៉ាន់, ការធ្វើដំណើរទៅតាមការណាត់ជួបផ្នែកពេទ្យ។

ច្បាប់នៃក្រសួង DSHS កំណត់ឲ្យតំលៃភាគរយទៅជាចំនួននៃជំនួយ

Janet មានសំរាប់ ADL ឬ IADL នីមួយៗដែលត្រូវសំរេចឲ្យបានមុនគេ។  តំលៃភាគរយ ពិនិត្យមើលចំពោះរបស់ពីរ:

- ទោះបីជាមានជំនួយការឧបត្ថម្ភក្រៅផ្លូវការណាមួយសំរាប់ ADL/IADL នីមួយៗ ដែលត្រូវសំរេចឲ្យមុនគេ; និង
- តើមានជំនួយប៉ុន្មាន បើសិនជាមានណាមួយ។

នេះគឺជាតារាងអំពីតែ Janet និង ADLs/IADLs ដែលត្រូវសំរេចឲ្យមុនគេរបស់គាត់។  Janet មានជំនួយមួយ ចំណែក ឬជំនួយអាចមានសំរាប់ការស្លៀកពាក់, ការផ្លាស់ប្តូរ, និងការរៀបចំអាហារពី Bill ។  Janet មិនមានជំនួយណាមួយ ឬអាចមានជំនួយ (លើកលែងតែមកអ្នកផ្តល់ការមើលថែដែលបានបង់ប្រាក់របស់គាត់) សំរាប់ការងូតទឹក, អនាម័យផ្ទាល់ខ្លួន, ឬការធ្វើដំណើរទៅតាមការណាត់ជួបផ្នែកពេទ្យ។ Janet មិនត្រូវការ ជំនួយណាមួយពីអ្នកផ្តល់ការមើលថែដែលបានបង់ប្រាក់របស់គាត់ ជាមួយនឹង ការងារក្នុងផ្ទះ ឬការទៅទិញអីវ៉ាន់។.

ជំនួយដែលអាចមានសំរាប់អ្វីៗទាំងអស់ ប៉ុន្តែការស្លៀកពាក់, ការផ្លាស់ប្តូរកន្លែង និងការរៀបចំអាហារ គឺត្រូវសរសេរ n/a (មិនអាចអនុវត្តបាន)។ នៅក្នុងតារាងខាងក្រោម ហេតុអ្វីពាក្យ "n/a" ត្រូវបានសរសេរចុះសំរាប់ ជំនួយដែលអាចមានសំរាប់អ្វីៗផ្សេងទៀត? N/A ត្រូវសរសេរចុះនៅពេល:

- គឺគ្មានជំនួយអាចមានសំរាប់ជួយ (មិនជួបតាម);
- ជំនួយទាំងអស់គឺអាចមានទទួល (ជួបតាម);
- ADL/IADL មិនបានកើតឡើងទេ ពីព្រោះអ្នកមិនអាច ឬអ្នកមិនមានអ្នកផ្តល់ការបំរើ;
- ADL/IADL មិនបានកើតឡើងទេ ពីព្រោះអ្នកបានបដិសេធជំនួយសំរាប់ឲ្យជួយ។

| ADLs/IADLs | ស្ថានភាព | ជំនួយដែលអាចមាន | តំលៃភាគរយ |
|---|---|---|---|
| ការស្លៀកពាក់ | បានជួបមួយចំណែក | ½ - ¾ | .35 |
| ការងូតទឹក | មិនបានជួប | N/A (មិនអាចអនុវត្ត) | 1 |
| អនាម័យផ្ទាល់ខ្លួន | មិនបានជួប | N/A (មិនអាចអនុវត្ត) | 1 |
| ការផ្លាស់ប្តូរកន្លែង | បានជួបមួយចំណែក | ½ ទៅ ¾ នៃពេល។ | .5 |
| ការរៀបចំអាហារ | Pបានជួបមួយចំណែក | ½ ទៅ ¾ នៃពេល។ | .1 |
| ការងារក្នុងផ្ទះ | បានដល់លក្ខណសម្បត្តិ | N/A (មិនអាចអនុវត្ត) | 0 |
| ការទៅទិញអីវ៉ាន់ | បានដល់លក្ខណសម្បត្តិ | N/A (មិនអាចអនុវត្ត) | 0 |
| ការធ្វើដំណើរតាម ការណាត់ជួបពេទ្យ | មិនបានជួប | N/A (មិនអាចអនុវត្ត) | 1 |

សរុបចំនួនតំលៃភាគរយ = 3.95

ចំនួនសរុបនៃ ADLs/IADLs ដែលត្រូវសំរេចឲ្យមុនគេ = 8

វិធានការទី 1 និង ទី 2 គឺបូកបញ្ចូលទៅនឹងចំនួនសរុបនៃចំនួនភាគរយ និងចំនួនសរុបនៃ ADLs/IADLs ដែលត្រូវសំរេចឲ្យមុនគេ។ ចូរមើលខាងលើ។

វិធានការទី 3 គឺចែកចំនួនសរុបនៃចំនួនភាគរយ ជាមួយនឹងចំនួននៃ ADLs/IADLs ដែលមានសិទ្ធិទទួល។ ចំនួននេះគឺចំនួន A ។ 3.95 ÷ 8 = .49375 = ចំនួន A ។ ចំនួននេះគឺតំឡើងខ្ទង់ទៅ .49 ។

វិធានការទី 4 គឺដកចំនួន A ពី 1 ។ 1 – .49 = 0.51 ។ ចំនួននេះគឺចំនួន B ។

វិធានការទី 5 គឺចែកចំនួន B នឹង 3 ។ 51 ÷ 3 = .17 ។ ចំនួននេះគឺចំនួន C ។

វិធានការទី 6 គឺបូកចំនួន A ទៅនឹងចំនួន C ។ .49 + .17 = .66 ។ ចំនួននេះគឺចំនួន D ។

វិធានការទី 7 គឺគុណចំនួន D ទៅនឹងមូលដ្ឋានម៉ោងរបស់ Janet (ដែលមានចំនួន 115) ។ 115 x .66 = 75.9 ។ ចំនួននេះគឺគិតឡើងខ្ពង់ទៅ 76 ។ នេះគឺជាចំនួនម៉ោងនៃការមើលថែផ្ទាល់ខ្លួន ដែល Janet នឹងទទួលក្នុងខែនិមួយៗ។

មូលដ្ឋានម៉ោងរបស់ Janet នឹងត្រូវកាត់បន្ថយ 39 ម៉ោងក្នុងមួយខែ ពីព្រោះ Bill រៀបចំអាហារពេលព្រឹក និងថ្ងៃត្រង់របស់គាត់ នៅចុងសប្តាហ៍, អាហារពេលល្ងាចរៀងរាល់យប់, ជួយជាមួយការផ្លាស់ប្តូរកន្លែងនិងការ ស្លៀកពាក់, ហើយនិងទៅទិញអីវ៉ាន់និងការងារក្នុងផ្ទះទាំងអស់ ។ ( 115 - 76 = 39 ម៉ោងតិចជាងមុនក្នុងមួយខែ)។

## តារាងសំរាប់ការឧបត្ថម្ភក្រៅផ្លូវការ

| ថ្នាំទាទា | ការធ្វើដោយខ្លួនឯង | ស្ថានភាព | ជំនួយដែលអាចមាន | តំលៃភាគរយ |
|---|---|---|---|---|
| ការគ្រប់គ្រងនៃថ្នាំពេទ្យ | វិន័យអនុវត្តសំរាប់គ្រប់ច្បាប់លើកលែងនៅតែឯងគឺមិនរាប់បញ្ចូលទេ | មិនបានជួប | N/A (មិនអាចអនុវត្ត) | 1 |
| | | បានដល់លក្ខណសម្បត្តិ | N/A (មិនអាចអនុវត្ត) | 0 |
| | | បដិសេធ | N/A (មិនអាចអនុវត្ត) | 0 |
| | | បានជួបមួយចំណែក | <1/4 ដង | .9 |
| | | | ¼ ទៅ ½ ដង | .7 |
| | | | ½ ទៅ ¾ ដង | .5 |
| | | | >3/4 ដង | .3 |
| **ADLs** **គ្មានការណាត់ជួប** | **ការធ្វើដោយខ្លួនឯង** | **ស្ថានភាព** | **ជំនួយដែលអាចមាន** | **តំលៃភាគរយ** |
| គ្រែចល័ត, ផ្លាស់ប្តូរ, ដើរក្នុងបន្ទប់, ការបរិភោគ, ការប្រើបង្គន់ | វិន័យអនុវត្តសំរាប់គ្រប់ច្បាប់លើកលែង: មិនបានកើតឡើង/អតិថិជនមិនអាចធ្វើបាន និង មិនបានកើតឡើងគ្មានអ្នកផ្តល់ការមើលថែ = 1; | មិនបានជួប | N/A (មិនអាចអនុវត្ត) | 1 |
| | | បានដល់លក្ខណសម្បត្តិ | N/A (មិនអាចអនុវត្ត) | 0 |
| | មិនបានកើតឡើង/អតិថិជនបដិសេធ និងភាពឯករាជ្យមិនត្រូវបានរាប់បញ្ចូលទេ។. | បដិសេធ | N/A (មិនអាចអនុវត្ត) | 0 |
| | | បានជួបមួយចំណែក | <1/4 ដង | .9 |
| | | | ¼ ទៅ ½ ដង | .7 |

| | | | | |
|---|---|---|---|---|
| | | | ½ ទៅ ¾ ដង | .5 |
| | | | >3/4 ដង | .3 |
| **ADLs** ដែលបានដាក់កំណត់ពេល | **ការធ្វើដោយខ្លួនឯង** | **ស្ថានភាព** | **ជំនួយដែលអាចមាន** | **តំលៃភាគរយ** |
| ការស្លៀកពាក់, អនាម័យផ្ទាល់ខ្លួន, ការងូតទឹក | វិន័យអនុវត្តសំរាប់គ្រប់ច្បាប់លើកលែង: មិនបានកើតឡើង/អតិថិជនមិនអាចធ្វើបាន និង មិនបានកើតឡើងគ្មានអ្នកផ្តល់ការមើលថែ = 1; | មិនបានជួប | N/A (មិនអាចអនុវត្ត) | 1 |
| | | បានដល់លក្ខណសម្បត្តិ | N/A (មិនអាចអនុវត្ត) | 0 |
| | មិនបានកើតឡើង/អតិថិជនបដិសេធ និងភាពឯករាជ្យមិនត្រូវបានរាប់បញ្ចូលទេ។ | បដិសេធ | N/A (មិនអាចអនុវត្ត) | 0 |
| | | បានជួបមួយចំណែក | <1/4 ដង | .75 |
| | | | ¼ ទៅ ½ ដង | .55 |
| | | | ½ ទៅ ¾ ដង | .35 |
| | | | >3/4 ដង | .15 |
| **IADLs** | **ការធ្វើដោយខ្លួនឯង** | **ស្ថានភាព** | **ជំនួយដែលអាចមាន** | **តំលៃភាគរយ** |
| ការរៀបចំម្ហូបអាហារ, ការងារក្នុងផ្ទះធម្មតា, ការទិញអីវ៉ាន់សំខាន់ៗ | វិន័យអនុវត្តសំរាប់គ្រប់ច្បាប់លើកលែងទៅតែឯងគឺមិនរាប់បញ្ចូលទេ | មិនបានជួប | N/A (មិនអាចអនុវត្ត) | 1 |
| | | បានដល់លក្ខណសម្បត្តិ | N/A (មិនអាចអនុវត្ត) | 0 |
| | | បដិសេធ | N/A (មិនអាចអនុវត្ត) | 0 |
| | | បានជួបមួយចំណែក | <1/4 ដង | .3 |
| | | | ¼ ទៅ ½ ដង | .2 |
| | | | ½ ទៅ ¾ ដង | .1 |
| | | | >3/4 ដង | .05 |
| **IADLs** | **ការធ្វើដោយខ្លួនឯង** | **ស្ថានភាព** | **ជំនួយដែលអាចមាន** | **តំលៃភាគរយ** |
| ការធ្វើដំណើរទៅពេទ្យ | វិន័យអនុវត្តសំរាប់គ្រប់ច្បាប់លើកលែងទៅតែឯងគឺមិនរាប់បញ្ចូលទេ. | មិនបានជួប | N/A (មិនអាចអនុវត្ត) | 1 |

| | | | | |
|---|---|---|---|---|
| | | បានដល់លក្ខណសម្បត្តិ | N/A (មិនអាចអនុវត្ត) | 0 |
| | | បដិសេធ | N/A (មិនអាចអនុវត្ត) | 0 |
| | | បានជួបមួយចំណែក | <1/4 ដង | .9 |
| | | | ¼ ទៅ ½ ដង | .7 |
| | | | ½ ទៅ ¾ ដង | .5 |
| | | | >3/4 ដង | .3 |
| គន្លឹះសញ្ញា:<br><br>> មានន័យថាធំជាង<br><br>< មានន័យថាតិចជាង | | | | |

## កន្លែងបោកខោអាវនៅខាងក្រៅ, ការទិញជួរអីវ៉ាន់, ឬអុសកំដៅ:

នៅពេលអ្នករស់នៅតាមផ្ទះ ការកែតំរូវចំពោះម៉ោងមើលថែរបស់អ្នកគឺបានកែតំរូវ នៅពេលដែលអ្នកមានករណី មួយឬច្រើនដូចតទៅនេះ:

- កន្លែងបោកខោអាវនៅខាងក្រៅ: អ្នកគ្មានម៉ាស៊ីនបោក/ ម៉ាស៊ីនបក់ក្នុងផ្ទះរបស់អ្នកផ្ទាល់។ អ្នកមើលថែមានបង់ឈ្នួល របស់អ្នកត្រូវតែស្ថិតនៅកន្លែងបោកខោអាវរបស់អ្នកនៅពេលកំពុងបោកនិងបក់។

- អ្នករស់ចម្ងាយ 45 នាទីពីទីផ្សារដែលមានសេវាគ្រប់យ៉ាងឬ ឱសថស្ថាន។.

- ប្រភពនៃកំដៅតែមួយរបស់អ្នកគឺអុស និងអ្នកត្រូវការជំនួយជាមួយនឹងភារៈកិច្ច ដូចជាបំបែកអុស, គរអុស, ឬយកអុសមកក្នុងផ្ទះ។.

អ្នកប្រហែលមិនអាចទទួលចំនួនម៉ោងបន្ថែមខ្លះទៀតទេ នៅពេលអ្នករស់នៅចម្ងាយលើសពី 45 នាទីពីទីផ្សារ ដែលមានសេវាគ្រប់យ៉ាងឬឱសថស្ថាន ឬត្រូវការឧបត្ថម្ភអុស បើអ្នកទទួលជំនួយពីការឧបត្ថម្ភក្រៅផ្លូវការ។ (ការឧបត្ថម្ភក្រៅផ្លូវការមិនមានការប៉ះពាល់ម៉ោងសំរាប់ការទៅបោកសំលៀកបំពាក់នៅហាងបោកអ៊ុតខាងក្រៅទេ)។ ជំនួយដែលអ្នកទទួលពីមិត្តសំឡាញ់, អ្នកជិតខាង, ឬសមាជិកគ្រួសារគឺហៅថាការឧបត្ថម្ភក្រៅផ្លូវការ។ ការឧបត្ថម្ភក្រៅផ្លូវការក៏មានរួមទាំងធនធានសហគមន៍ដូចជាក្រុមវិហារកាតុលិកជាដើម។ យើងមិនបង់ប្រាក់សំរាប់ ការឧបត្ថម្ភក្រៅផ្លូវការទេ។ យើងប្រើពាក្យដូចតទៅនេះ នៅពេលពិភាក្សាអំពីការឧបត្ថម្ភក្រៅផ្លូវការ::

- **បានជួបតាម:** នៅពេលការឧបត្ថម្ភក្រៅផ្លូវការជួបគ្រប់សេចក្ដីត្រូវការរបស់អ្នកសំរាប់ជួយជាមួយភារៈកិច្ច។ ឧទាហរណ៍ អ្នកមិនអាចទៅទិញអីវ៉ាន់របស់អ្នក និងអ្នករស់នៅចម្ងាយ 45 នាទីពីទីផ្សារដែលមានសេវាគ្រប់យ៉ាង។ កូនស្រីរបស់អ្នក ដែលមិនបង់ឈ្នួល ទៅទិញអីវ៉ាន់គ្រប់យ៉ាងរបស់អ្នក។.

- **បានជួបមួយចំណែក:** នៅពេលការឧបត្ថម្ភក្រៅផ្លូវការជួបមួយភាគតាមសេចក្ដីត្រូវការរបស់អ្នក សំរាប់ជួយដល់ ភារៈកិច្ច។ ឧទាហរណ៍ ដូចជា ឱសថស្ថានទិញថ្នាំនៅចម្ងាយលើសពី 45 ម៉ៃពីផ្ទះអ្នក។ អ្នកមិនអាចបើកបរបាន។ អ្នកជិតខាងរបស់អ្នក ដែលមិនមានបង់ឈ្នួល, ជូនអ្នកទៅ 2 ដងក្នុងមួយខែ។.

    - បើសេចក្ដីត្រូវការរបស់អ្នកសំរាប់ជួយជាមួយនឹងភារៈកិច្ច បានជួបមួយចំណែកតាមការឧបត្ថម្ភក្រៅផ្លូវការ នោះយើងសង្កេតមើលថា តើជំនួយជាញឹកញាប់នេះគឺត្រូវការឬទេ។ នៅពេលនោះ យើងរកមើលថា តើ ញឹកញាប់យ៉ាងណានៃការឧបត្ថម្ភក្រៅផ្លូវការនេះ ដែលអាចមានដើម្បីជួបនឹងសេចក្ដីត្រូវការនេះ:

        - នៃពេល (កំណត់ចំណាំ: គ្មានការកាត់បន្ថយត្រូវបានធ្វើ នៅពេលអ្នករស់នៅចម្ងាយ 45 នាទីពីទីផ្សារដែលមាន សេវាគ្រប់យ៉ាងឬឱសថស្ថាន ឬជាមួយការឧបត្ថម្ភអុសទេ ដ៏រាបណាអ្នកអ្នកមានការឧបត្ថម្ភក្រៅផ្លូវការតិចជាង ¼ នៃពេលជាមួយនឹងរឿងទាំងនេះ);;

            - ¼ ទៅ ½ នៃពេល។
            - ½ ទៅ ¾ នៃពេល។
            - លើសពី ¾ នៃពេលវេលា.

- **មិនបានជួប:** គឺគ្មានការឧបត្ថម្ភក្រៅផ្លូវការ។ ឧទាហរណ៍ អ្នកមិនអាចទៅទិញអីវ៉ាន់របស់អ្នកនិងគ្មានជនណា ម្នាក់នឹងទិញអីវ៉ាន់ឲ្យអ្នក។.

- **អតិថិជនបដិសេធ:** នេះមានន័យថា អ្នកមិនចង់បានជំនួយជាមួយការទិញអីវ៉ាន់ ឬការឧបត្ថម្ភអុសដុតទេ។.

**ឧទាហរណ៍នានា:**

កំណត់សំគាល់: ទំនាក់ទំនងទៅនឹងច្បាប់ដែលរកផ្លូវដោះស្រាយជាមួយនឹងកន្លែងបោកខោអាវនៅខាងក្រៅ, ការទៅទិញអីវ៉ាន់, និងអុសដុតកំដៅគឺនៅបន្ទាប់ពីឧទាហរណ៍ក្រោយបង្អស់។.

**ឧទាហរណ៍ #1**:

Jamie មានអាយុ 42 ឆ្នាំ។ គាត់រស់នៅតែម្នាក់ឯង ក្នុងផ្ទះចាស់តូចមួយ ដែលត្រូវបានកំដៅផ្ទះដោយ ចង្ក្រានដុតអុសចាស់មួយ។ Jamie មានជំងឺហើមសន្លាក់ឆ្អឹង និងបញ្ហាដកដង្ហើមពីជំងឺហឺត។ គាត់មិនអាចធ្វើអ្វី ដែលចាំបាច់ដើម្បីរក្សាផ្ទះគាត់ឲ្យមានកំដៅទេ។ គាត់ត្រូវការអ្នកមើលថែមានបង់ឈ្នួលរបស់គាត់ដើម្បីជួយពុះអុស, រៀបគរទុក, នឹងយកអុសទុក។ Jamie ទទួលបាន 158 ម៉ោង នៃសេវាមើលថែផ្ទាល់ខ្លួននៅតាមផ្ទះក្នុងមួយខែ។.

Jamie គ្មានជំនួយអុសដុតកំដៅមកពីមិត្តសំឡាញ់, អ្នកជិតខាង, សមាជិកគ្រួសារ, ឬធនធានសហគមន៍ ដូចជាក្រុមវិហារកាតូលិក។ សេចក្តីត្រូវការរបស់គាត់សំរាប់ជួយអុសដុតកំដៅគឺ "មិនបានជួប" ដោយ ការឧបត្ថម្ភក្រៅផ្លូវការ។ ពីព្រោះអុសគឺជាប្រភពតែមួយគត់នៃកំដៅ, គាត់ទទួលម៉ោងច្រើនទៀត ដើម្បីអ្នកមើលថែ មានបង់ឈ្នួលរបស់គាត់អាចជួយកិច្ចការនេះ។

នេះគឺជាតារាងអំពីតែ Jamie និងសេចក្តីត្រូវការសំរាប់ជំនួយអុសដុតកំដៅ។ * ជំនួយអាចមាននៅក្នុងជួរបន្ទាត់ ទីបីគឺចុះថា N/A (មិនអាចអនុវត្ត) ពីព្រោះ Janet មិនមាន ការឧបត្ថម្ភក្រៅផ្លូវការណាមួយអាចមានជួយ ពីរឿងអុសដុតកំដៅទេ។

| លក្ខណៈការរស់នៅ | ស្ថានភាព | ជំនួយដែលអាចមាន | បូកបញ្ចូលម៉ោង |
|---|---|---|---|
| ការឧបត្ថម្ភអុសបានប្រើជាប្រភពស្នូលនៃកំដៅ | មិនបានជួប | N/A (មិនអាចអនុវត្ត) | 8 |

ម៉ោង = 158

បូកបញ្ចូលម៉ោង = 8

ម៉ោងសេវាបំរើរបស់ Jamie និងបង្កើន 8 ម៉ោងក្នុងមួយខែ ពីព្រោះគាត់ត្រូវការជំនួយជាមួយការកំដៅផ្ទះ នឹងអុស។ ( 158 + 8 = 166 ម៉ោងក្នុងមួយខែ។)

**ឧទាហរណ៍ #2**:

Clara មានអាយុ 85 ឆ្នាំ។ គាត់បានធ្លាប់រស់នៅអាគារជួលចាស់ ដែលមិនមានម៉ាស៊ីនបោកឬបក់នៅក្នុងអាគារ។ អ្នកមើលថែមានបង់ឈ្នួលរបស់គាត់បានយកសំលៀកបំពាក់ទៅកន្លែងហាងបោកសំលៀកបំពាក់ នៅជិតខាង ហើយនៅរង់ចាំកន្លែងបោកអ៊ុតរហូតទាល់តែរួចអស់។ Clara មានចំនួនសេវាបំរើ 65 ម៉ោងក្នុងមួយខែ ហើយ 8 ម៉ោងបានត្រូវបូកបញ្ចូល ពីព្រោះគាត់មានម៉ាស៊ីនបោកសំលៀកបំពាក់នៅក្រៅពីផ្ទះ។ Clara បានទទួលសរុប 73 ម៉ោងក្នុងមួយខែ។ 65 + 8 = 73 ។

Clara ពេលថ្មីៗនេះបានប្តូរលំនៅទៅទៅជិតផ្ទះកូនស្រីរបស់គាត់ ហើយផ្ទះថ្មីមានម៉ាស៊ីនបោកឬបក់សំលៀកបំពាក់។ Clara មានការវាយតំលៃប្រចាំឆ្នាំរបស់គាត់មិនយូរប៉ុន្មាននៅក្រោយពេលគាត់បានប្តូរលំនៅ។ គ្មានអ្វី នៅក្នុងការវាយតំលៃរបស់គាត់បានផ្លាស់ប្តូរទេ លើកលែងតែអ្នកមើលថែមានបង់ឈ្នួលរបស់គាត់ លែងត្រូវការ ទៅកន្លែងបោកសំលៀកបំពាក់ ហើយនៅកន្លែងម៉ាស៊ីនបោករបស់អ្នកស្រី Clara ។

Clara លែង មានលក្ខណសម្បត្តិសំរាប់ទទួល 8 ម៉ោងសំរាប់កន្លែងបោកសំលៀកបំពាក់នៅខាងក្រៅផ្ទះទៀតហើយ។ Clara ទទួលចំនួន 65 ម៉ោងក្នុងមួយខែ។ គាត់នឹងមិនបានទទួល 8 ម៉ោងបន្ថែមទៀតទេ។

**ឧទាហរណ៍ #3**:

Scott គឺជាអតិថិជនមានអាយុ 64 ឆ្នាំ ដែលរស់នៅតំបន់ស្រុកស្រែដាច់ស្រយ៉ាល។ គឺចម្ងាយលើសពី 45 នាទី ពីផ្ទះរបស់គាត់ទៅទីផ្សារដែលមានសេវាគ្រប់យ៉ាងឬឱសថស្ថាន។ គាត់រស់នៅក្នុងផ្ទះចាស់មួយ ដែលកំដៅផ្ទះ ដោយប្រើតែចង្ក្រានដុតអុស។ Scott រស់នៅតែម្នាក់ឯងនិងកំសាន្តសប្បាយពេលវេលារបស់គាត់នៅស្រុកស្រែ។
គាត់ទទួលបាន 111 ម៉ោងនៃសេវាមើលថែផ្ទាល់ខ្លួននៅតាមផ្ទះក្នុងមួយខែ។.

កូនរបស់ Scott ឈ្មោះ Ben មកសួរសុខទុក្ខគាត់ពីរដងក្នុងមួយអាទិត្យ។ នៅពេលគាត់មកសួរសុខទុក្ខ គាត់ពុះបំបែកអុសសំរាប់គ្រប់ពីរថ្ងៃ។ អុសក៏ត្រូវការយកចូលទៅក្នុងផ្ទះផងដែរ។ ផ្ទះរបស់ Scott គឺតូច ដូច្នេះ Ben អាចយកអុសចូលគ្រប់គ្រាន់បានសំរាប់តែ 2 ថ្ងៃប៉ុណ្ណោះ។ អ្នកមើលថែមានប្រាក់ឈ្នួលរបស់ Scott ពុះបំបែកអុស 3 ដងក្នុងមួយអាទិត្យ។ គាត់ក៏យកចូលក្នុងគ្រប់គ្រាន់សំរាប់តែ 2 ថ្ងៃចុងក្រោយ 3 ដង ក្នុងមួយអាទិត្យ។ Scott ត្រូវការពុះបំបែកអុសនិងយកចូលក្នុង 4 ដង ក្នុងមួយអាទិត្យ។ Ben ជួងម្តង ក្នុងចំណោម 4 ដងទាំងនេះ ដែលគឺ ¼ នៃពេលវេលា។ ¼ ពេលគឺជាភាគបែងនៃ ¼ - ½ ។ សេចក្តីត្រូវការរបស់ Scott សំរាប់ជំនួយជាមួយនឹងអុសដុតកំដៅគឺ "បានជួបមួយចំណែក" ពីរ ¼ ទៅ ½ នៃពេល។ ក្នុងការទទួលជំនួស 8 ម៉ោងបន្ថែមក្នុងមួយខែ ពីព្រោះតែគាត់មានតែអុសដុតកំដៅ, Scott នឹងទទួល បាន 6 ម៉ោងបន្ថែមក្នុងមួយខែ ពីព្រោះតែមានជំនួយ។

Scott ត្រូវការជំនួយជាមួយនឹងការទៅទិញអីវ៉ាន់ ដូច្នេះអ្នកមើលថែមានប្រាក់ឈ្នួលរបស់គាត់ទៅទិញអីវ៉ាន់ឲ្យ គាត់។ Scott នឹងទទួលបាន 5 ម៉ោងបន្ថែមក្នុងមួយខែសំរាប់រឿងនេះ ពីព្រោះរស់នៅចម្ងាយលើសពី 45 នាទី ពីទីផ្សារដែលមានសេវាគ្រប់យ៉ាងឬឱសថស្ថាន។ សេចក្តីត្រូវការរបស់ Scott សំរាប់ជួយ ទៅទិញអីវ៉ាន់នៅ ឆ្លាយគឺ "មិនបានជួប"។

នេះគឺជាតារាងតែអំពី Scott និងការកែតំរូវដែលបានកែចំពោះម៉ោងរបស់គាត់សំរាប់ការរស់នៅចម្ងាយលើសពី 45 នាទីពីទីផ្សារដែលមានសេវាគ្រប់យ៉ាងឬឱសថស្ថាន និងអុសកំដៅ។ ជំនួយដែលអាចមានគឺបានចុះ N/A សំរាប់ការរស់នៅចម្ងាយលើសពី 45 នាទី ពីទីផ្សារ ពីព្រោះ Scott មិនមានការឧបត្ថម្ភក្រៅផ្លូវការទេជាមួយ រឿងនេះ។

| លក្ខណៈការរស់នៅ | ស្ថានភាព | ជំនួយដែលអាចមាន | បូកបញ្ចូលម៉ោង |
|---|---|---|---|
| អតិថិជនរស់នៅចម្ងាយលើសពី 45 នាទីពីទីផ្សារដែលត្រូវការចាំបាច់ (ដែលមានន័យថា គាត់រស់នៅចម្ងាយលើសពី 45 នាទី តែទៅ ពីសេវាទីផ្សារទាំងស្រុង)។. | មិនបានជួប | N/A (មិនអាចអនុវត្ត) | 5 |
| ការឧបត្ថម្ភអុសបានប្រើជាប្រភពស្នូលនៃកំដៅ | បានជួបមួយចំណែក | ចន្លោះ½ និង ¾ នៃពេល | 4 |

ម៉ោងសេវាបំរើរបស់ Scott និងបង្កើន 9 ម៉ោងក្នុងមួយខែ ពីព្រោះគាត់ត្រូវការជំនួយជាមួយការកំដៅផ្ទះ នឹងអុស។ ( 111 + 9 = 120 ម៉ោងក្នុងមួយខែ។)

**http://apps.leg.wa.gov/wac/default.aspx?cite=388-106-0130**